ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

# ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ
# ទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពល

**ឆ្នាំ ២០១២**

**មាតិកា**

មាតិកា ..................................................................................................................................... i
បុព្វកថា ................................................................................................ Error! Bookmark not defined.
៣. សេចក្ដីសង្ខេប ........................................................................................................................................ 3
៤. សេចក្ដីផ្ដើម .......................................................................................................................................... 4
៥. ពិពណ៌នាពីស្ថានភាពវិស័យឧស្សាហកម្ម និងថាមពល ............................................................................ 5
៥.១. ស្ថានភាពឧស្សាហកម្មកម្មន្តសាល និង ឧស្សាហកម្មតូច និងសិប្បកម្ម ............................................ 5
៥.២. ស្ថានភាពផលិត និងផ្គត់ផ្គង់ថាមពល ............................................................................................ 8
៦. ផលប៉ះពាល់តាមវិស័យ អនុវិស័យនិងហានិភ័យអាកាសធាតុក្នុងប្រទេសកម្ពុជា ....................................... 8
៧. គោលនយោបាយ និងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ............................ 9
៧.១. វិស័យឧស្សាហកម្ម ....................................................................................................................... 9
ក. ប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម ....................................................................................... 9
ខ. ឧស្សាហកម្មបៃតង (Green Industry) ............................................................................................. 10
គ. ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកំណត់ចំណុចបំពុលខ្លាំង និងការផ្ទេរបច្ចេកវិទ្យាអំណោយផលដល់បរិស្ថាន (Hot-Spot & TEST) ........................................................................... 12
ឃ. ការគ្រប់គ្រងសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ............................................................................. 13
៧.២. ការអភិវឌ្ឍន៍វិស័យថាមពល ......................................................................................................... 14
ក. គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល ......................................................................................... 14
ខ. ការអភិវឌ្ឍន៍វិស័យថាមពលដែលអំណោយផលដល់បរិស្ថាន ................................................................. 15
៨. វិធានការឆ្លើយតបតាមវិស័យដែលមានស្រាប់ និងអាចអនុវត្តបានចំពោះការប្រែប្រួលអាកាសធាតុ ..16
៨.១. ចក្ខុវិស័យ .................................................................................................................................... 16
៨.២. បេសកកម្ម .................................................................................................................................. 16
៨.៣. គោលដៅ និងគោលបំណង ............................................................................................................. 17
៨.៤.ក្របខណ្ឌយុទ្ធសាស្ត្រ ........................................................................................................................ 18
៨.៥. កម្មវិធីដែលត្រូវអនុវត្តបន្ត ............................................................................................................ 22
៩. សុពលភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ .........................................................................................22

១០. សន្និដ្ឋាន.........................................................................................................22
១២. ឯកសារយោង.........................................................................................................23

# បុព្វកថា

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រ៉ែ និងថាមពល។ វិស័យទាំងបីនេះ បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋឲ្យស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ក៏ដូចជា គោលដៅអភិវឌ្ឍន៍សហវត្សកម្ពុជា។ ការអភិវឌ្ឍន៍វិស័យទាំងនេះ បានផ្សាភ្ជាប់ជាមួយនឹងការគិតពិចារណាយ៉ាងល្អិតល្អន់លើតុល្យភាពសេដ្ឋកិច្ច សង្គម និងបរិស្ថានប្រកបដោយចីរភាពផងដែរ។

វិស័យឧស្សាហកម្ម និងថាមពលបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ដំណើរការផលិតកម្មនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ដើម្បីផ្តល់នូវកំណើនការងារ កំណើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ជួយបង្កើនថវិកាជាតិ ជាពិសេសគឺកំណើនផលិតផលជាតិសរុប សំរាប់គាំទ្រដល់សេដ្ឋកិច្ចជាតិ និងសង្គម។ ចំណែកវិស័យថាមពលក៏ជាតំរូវការចាំបាច់សំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់រូប និងសំរាប់ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម កសិកម្ម និងវិស័យផ្សេងៗទៀតផងដែរ។

គោលបំណងសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងថាមពល ត្រូវធ្វើឲ្យមានភាពស៊ីសង្វាក់គ្នា និងមានតុល្យភាពទាំងផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានតាមរយៈការទទួលយក និងការផ្ទេរបច្ចេកវិទ្យាក្នុងវិស័យទាំងពីរនេះ ឲ្យមានលក្ខណៈបៃតងជាបណ្តើរៗ សំរាប់ពេលអនាគត។

ដោយផ្អែកលើលក្ខណៈបច្ចេកទេស យើងត្រូវពង្រឹង និងពង្រីកនូវសកម្មភាពមួយចំនួនដូចជា៖ ការអភិវឌ្ឍន៍បច្ចេកវិទ្យាស្អាតតាមរយៈ ការផ្ទេរបច្ចេកវិទ្យាដែលអំណោយផលដល់បរិស្ថាន ការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម និងការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញតាមរយៈ ថាមពលពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ថាមពលវារីអគ្គិសនី ថាមពលជីវម៉ាស និងថាមពលជីវឧស្ម័នជាដើម ដែលជាប្រធានបទដ៏ចាំបាច់ត្រូវយកមកអនុវត្ត។

ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលនេះ ជាផែនទីបង្ហាញផ្លូវជាក់លាក់សំរាប់ជួយដល់វិស័យឯកជន ដើម្បីមានផែនការទុកជាមុន នៅក្នុងការអនុវត្តន៍ និងដោះស្រាយពីបញ្ហាដែលអាចកើតមានឡើង តាមរយៈការប្រើប្រាស់ធនធាន និងការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ការកាត់បន្ថយការបញ្ចេញសំណល់ និងការបំពុល ការផ្លាស់ប្តូរសារធាតុគ្រោះថ្នាក់ទៅជាសារធាតុគ្រោះថ្នាក់តិចតួច ឬជាសារធាតុដែលគ្មានគ្រោះថ្នាក់នៅតាមរោងចក្រ សហគ្រាស និងសិប្បកម្ម។ សកម្មភាពទាំងនេះ នឹងជួយបង្កើនផ្នែកផលិតភាព គុណភាព និងភាពប្រកួតប្រជែងរបស់រោងចក្រ សហគ្រាស និងសិប្បកម្មឲ្យមានភាពប្រសើរជាងមុន។ លើសពីនេះទៅទៀត ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនេះ ក៏ជាផែនទីបង្ហាញផ្លូវសំរាប់ភាគីពាក់ព័ន្ធដែលជាស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍នានា ជាពិសេសសំរាប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលយកមកអនុវត្តក្នុងការរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុផងដែរ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចូលរួម និងបន្តកិច្ចសហការលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រនេះ ជាមួយក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ព្រមទាំងមានកិច្ចសហការ និងជួយឧបត្ថម្ភពីសហគមន៍អឺរុប កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានាតាមរយៈកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។

**រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

## ៣. សេចក្តីសង្ខេប

ថ្វីត្បិតតែកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការចាប់ផ្តើមឧស្សាហូបនីយកម្មក៏ដោយ ក៏បញ្ហាការបំពុលដែលចេញពីវិស័យឧស្សាហកម្មមានលក្ខណៈគួរឲ្យកត់សំគាល់ផងដែរ បើផ្អែកលើប្រភេទនៃឧស្សាហកម្មផលិត ការផលិតថាមពលអគ្គិសនីដោយប្រើប្រាស់ប្រេងខ្មៅ ការអនុវត្តន៍ការគ្រប់គ្រងបរិស្ថានមិនបានល្អប្រសើរ ការប្រើប្រាស់បច្ចេកវិទ្យាដែលមិនអំណោយផលដល់បរិស្ថាន ការអនុវត្តន៍គេហកិច្ចមិនទាន់បានល្អប្រសើរ ការខ្វះខ្នាយក្នុងការប្រើប្រាស់ធនធាន និងការប្រើប្រាស់ថាមពលពុំទាន់មានប្រសិទ្ធភាព ដែលកត្តាទាំងនេះអាចបង្កឲ្យឧស្សាហកម្មក្នុងស្រុកប្រឈមនឹងការបំពុលបរិស្ថាន។

ដូច្នេះ ការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព នឹងក្លាយជាមធ្យោបាយដ៏ចាំបាច់មួយក្នុងការការពារ និងដោះស្រាយនូវរាល់ការធ្លាក់ចុះនៃធនធានធម្មជាតិ និងបញ្ហាបរិស្ថាន។ ការគ្រប់គ្រងគួរតែផ្តោតទៅលើយុទ្ធសាស្ត្រការពារទុកជាមុនជាជាងយុទ្ធសាស្ត្រឆ្លើយតប ឬយុទ្ធសាស្ត្រដោះស្រាយបញ្ហាបន្ទាប់ពីមានបញ្ហាទាំងនេះកើតឡើង។

ឯកសារផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពលនេះ មានចំនួន៨ ផ្នែកសំខាន់ៗដែលបានអត្ថាធិប្បាយពីខ្លឹមសារលំអិតដែលមានភាពស៊ីសង្វាក់គ្នាពីផ្នែកមួយទៅផ្នែកមួយ និងមានភ្ជាប់ឧបសម្ព័ន្ធមួយ៖ **ផ្នែកទី១** បានអត្ថាធិប្បាយនូវព័ត៌មានគោលអំពីផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពល។ **ផ្នែកទី២** បានពណ៌នាពីសវតា និងនីតិវិធីនានាលើការកសាងផែនការយុទ្ធសាស្ត្រនេះ រួមទាំងពន្យល់អំពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រដោយផ្អែកលើភាពបត់បែនដែលអាចអនុវត្តបាន កិច្ចសហការរបស់ភាគីពាក់ព័ន្ធ ការវិភាគ និងការវាយតម្លៃពីឥទ្ធិពលដែលមិនប៉ះពាល់ដល់ធុរៈកិច្ចវិស័យឯកជន និងផលប្រយោជន៍នៃការអនុវត្តន៍ផងដែរ។ **ផ្នែកទី៣** បានពណ៌នាពីស្ថានភាពទូទៅ ដែលទាក់ទងនឹង វិស័យឧស្សាហកម្មកម្មន្តសាល ឧស្សាហកម្មតូច និងសិប្បកម្ម ដែលក្នុងនោះមានស្ថិតិលំអិតពីប្រភេទ ចំនួនតួលេខដែលបានទទួលការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចាប់ពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១១ និងស្ថានភាពផលិត និងផ្គត់ផ្គង់ថាមពលនៅទូទាំងប្រទេសដែលមានសូចនករច្បាស់លាស់ក្នុងចន្លោះពេល ១០ ឆ្នាំរំកិលគឺឆ្នាំ២០១០ ដល់ឆ្នាំ ២០២០ និងឆ្នាំ ២០២០ ដល់ឆ្នាំ ២០៣០។ **ផ្នែកទី៤** បានវិភាគពីផលប៉ះពាល់ក្នុងវិស័យទាំងពីរនេះរួមមានការទទួលយកនូវបញ្ហានៃការប្រែប្រួលអាកាសធាតុ និងកំរិតបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងឧស្ម័នផ្សេងៗទៀតពីការអនុវត្តន៍ ដោយវិស័យឧស្សាហកម្មកម្មន្តសាល ឧស្សាហកម្មតូច និងសិប្បកម្មកន្លងមក។ **ផ្នែកទី៥** បានកំណត់ពីយុទ្ធសាស្ត្រទាំងឡាយសំរាប់ដោះស្រាយបញ្ហាចំបងៗរួមមានប្រសិទ្ធភាពថាមពល ឧស្សាហកម្មបៃតង ការផ្ទេរបច្ចេកវិទ្យាដែលមានលក្ខណៈអំណោយផលដល់បរិស្ថាន ការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាពក្នុងវិស័យឧស្សាហកម្ម និងការអភិវឌ្ឍន៍វិស័យថាមពលរួមមាន ប្រព័ន្ធថាមពលដើរដោយពន្លឺព្រះអាទិត្យទាំងប្រភេទលំនៅដ្ឋាន និង វារីអគ្គិសនីខ្នាតតូច និងមធ្យម រួមទាំងថាមពលអគ្គិសនីផលិតចេញពីជីវម៉ាស និងជីវឧស្ម័ន។ **ផ្នែកទី៦** បានលើកឡើង

អំពីវិធានការឆ្លើយតបតាមវិស័យដែលមានស្រាប់ និងអាចអនុវត្តបានចំពោះការប្រែប្រួលអាកាសធាតុ ដោយការកំណត់ចក្ខុវិស័យតាមរយៈការទទួលយក ការបន្សាំ ការការពារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបំបែកទៅជាបេសកម្ម គោលដៅ និងគោលបំណងលំអិត។ នៅក្នុងផ្នែកនេះក៏បានវិភាគជាយុទ្ធសាស្ត្រលើចំណុចខ្សោយ ចំណុចខ្លាំង បញ្ហាប្រឈមក្នុងវិស័យទាំងពីរ និងកម្មវិធីដែលត្រូវដោះស្រាយបន្តលើបញ្ហាប្រឈម និងពង្រឹងចំណុចដែលនៅខ្វះខាត។ **ផ្នែកទី៧** បានកំណត់យកសុពលភាពនៃផែនការយុទ្ធសាស្ត្រស្របតាមអាណត្តិរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល៥ឆ្នាំម្តង។ **និងផ្នែកទី៨** បានពន្យល់លំអិតពីការបែងចែកជាដំណាក់កាលនៃផែនការដោយចែកចេញជាពីរផ្នែកគឺៈ ទី១ ការទទួលយក និង ការបន្សាំ និងទី២ គឺការការពារ និង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

## ៤. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលបានកសាងក្នុងគោលបំណងចូលរួមសហការក្នុងការទទួលយក ការបន្សាំ ការការពារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុជាមួយវិស័យពាក់ព័ន្ធផ្សេងៗទៀត ក្នុងនោះមានក្រសួងបរិស្ថានជាអ្នកសំរបសំរួលការងារប្រែប្រួលអាកាសធាតុជាតិ។

ផែនការយុទ្ធសាស្ត្រនេះ នឹងត្រូវយកទៅអនុវត្តដោយអង្គភាពក្រោមចំណុះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាពិសេស អគ្គនាយកដ្ឋានឧស្សាហកម្ម និងអគ្គនាយកដ្ឋានថាមពលដែលជាសេនាធិការផ្ទាល់របស់ក្រសួងដែលត្រូវចាត់ចែង និងអនុវត្តទៅតាមការណែនាំ និងការតំរង់ទិសពីថ្នាក់ដឹកនាំរបស់ក្រសួងតាមការចាំបាច់។ ថ្នាក់ក្រោមជាតិដូចជា មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលគ្រប់ខេត្ត ក្រុង រាជធានីក៏ត្រូវយកផែនការយុទ្ធសាស្ត្រនេះទៅអនុវត្តបន្តទៅតាមរចនាសម្ព័ន្ធរបស់ខ្លួន និងភាគីពាក់ព័ន្ធពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា។

ការអនុវត្តន៍ផែនការនេះ យើងត្រូវវាយតម្លៃជាមុន និងពិនិត្យឲ្យបានស៊ីជំរៅទៅលើផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានលើវិស័យឧស្សាហកម្ម និងថាមពល និងតំរូវការជាក់ស្តែងនៃបរិបទសេដ្ឋកិច្ចសង្គម និងបរិស្ថានរបស់ខ្លួនធ្វើការសំរបសំរួល និងបត់បែនទៅតាមស្ថានភាពជាក់ស្តែងដែលអាចអនុវត្តបាន និងធ្វើយ៉ាងណាមិនដាក់បន្ទុក ឬ ធុរៈកិច្ចបន្ថែមដល់វិស័យឯកជនផងដែរ។

រោងចក្រ សហគ្រាស និងសិប្បកម្មដែលជាក្រុមគោលដៅ នឹងត្រូវបានយកចិត្តទុកដាក់យ៉ាងពិសេសពីផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពល ពីព្រោះគោលបំណងសំខាន់របស់ផែនការយុទ្ធសាស្ត្រនេះ គឺចង់ជួយឲ្យរោងចក្រ សហគ្រាស និងសិប្បកម្មទាំងនោះមានការការពារទុកជាមុន ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ធ្វើឲ្យមានប្រសិទ្ធភាពខ្ពស់ជាងមុនក្នុងការប្រើប្រាស់ថាមពល និងវត្ថុធាតុដើមនានា នឹងអាចកាត់បន្ថយការបញ្ចេញសំណល់ និងការបំពុលផ្សេងៗ នឹងដែលអាចសំរេចបាននូវការសន្សំសំចៃថវិកា ហើយអាចបង្កើនលទ្ធភាពចូលទៅក្នុងទីផ្សារអន្តរជាតិជាមួយប្រសិទ្ធភាពប្រសើរជាងមុនតាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗដែលមានអំណោយផលដល់បរិស្ថាន និងសេដ្ឋកិច្ច ហើយស្របពេលជាមួយគ្នារោងចក្រ សហគ្រាស និងសិប្បកម្មទាំងនោះនឹងមានសមត្ថភាពប្រកួតប្រជែងល្អប្រសើរថែមទៀត។

ការអភិវឌ្ឍន៍វិស័យថាមពលបានចូលរួមមួយចំណែកធំ ដើម្បីជំរុញល្បឿនសេដ្ឋកិច្ចជាតិ ពីព្រោះ ថាមពលមិនមែនត្រូវការសំរាប់តែជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ តែក៏មានសារៈសំខាន់សំរាប់វិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម និងសេដ្ឋកិច្ចផងដែរ។ យើងត្រូវពិនិត្យនូវការអនុវត្តន៍វិស័យថាមពលមួយណា ដោយថ្លឹងថ្លែងពីការវាស់វែងតុល្យភាពនៃផលចំណេញទាំងផ្នែកបរិស្ថាន សេដ្ឋកិច្ច វប្បធម៌ និងការទទួលខុសត្រូវសង្គម។ យើងត្រូវធ្វើការអភិវឌ្ឍន៍ស្របគ្នាទៅតាមទិសដៅយុទ្ធសាស្ត្រឲ្យមានផលចំណេញនូវគ្រប់ទិដ្ឋភាព ដើម្បីចូលរួមចំណែកក្នុងការអនុវត្តន៍វិស័យថាមពលដែលមានភាពបៃតង ដោយយើងគួរពិចារណាលើះ

- ការផលិតថាមពលច្រើនប្រភេទដូចជាៈ
    - ថាមពលពន្លឺព្រះអាទិត្យ
    - ថាមពលខ្យល់
    - ថាមពលវារីអគ្គិសនី
    - ថាមពលជីវម៉ាស
    - ថាមពលជីវឧស្ម័ន

លទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលនឹងផ្តល់ផលប្រយោជន៍តាមរយៈការទទួលបាននូវចំណេះដឹងអំពីវិធីសាស្ត្រចំណាយមានប្រសិទ្ធភាពដែលធ្វើឲ្យមានការកើនឡើងនូវផលិតភាព និងប្រសិទ្ធភាពផលិតកម្ម ហើយនៅពេលជាមួយគ្នានេះដែរបានធ្វើឲ្យមានការកាត់បន្ថយការបំពុលបរិស្ថានដល់រោងចក្រ សហគ្រាស និងសិប្បកម្មដែលមានស្រាប់។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពល អាចទទួលយកការពិនិត្យឡើងវិញ និងការកែសំរួលតាមការចាំបាច់។

ជាចុងក្រោយ គឺប្រជាជនកម្ពុជា និងប្រព័ន្ធអេកូឡូស៊ីទាំងមូល នឹងទទួលបានផលប្រយោជន៍ពីការកាត់បន្ថយការបំពុលបរិស្ថាន ដែលជាលទ្ធផលមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រនេះ។ ប្រជាជនកម្ពុជា ក៏នឹងទទួលបានផលប្រយោជន៍ផងដែរ ពីសក្តានុពលការងារកាន់តែច្រើនឡើងៗ នៅពេលដែលមានការពង្រីករោងចក្រ សហគ្រាស និងសិប្បកម្ម ដោយសារតែក្រុមហ៊ុនទាំងនោះមានប្រសិទ្ធភាពខ្ពស់ជាងមុន ហើយមានលទ្ធភាពពង្រីកអាជីវកម្មទៅកាន់ទីផ្សារអន្តរជាតិ។

## ៥. ពិពណ៌នាពីស្ថានភាពវិស័យឧស្សាហកម្ម និងថាមពល

### ៥.១. ស្ថានភាពឧស្សាហកម្មកម្មន្តសាល និង ឧស្សាហកម្មតូច និងសិប្បកម្ម

វិស័យឧស្សាហកម្ម បានរួមចំណែកក្នុងការអភិវឌ្ឍន៍ និងផលិតកម្មនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ដើម្បីផ្តល់នូវកំណើនការងារ បង្កើនផលិតភាព គុណភាព និងការប្រកួតប្រជែង ដែលជាការរួមចំណែកប្រមូលនូវថវិកាជាតិក្នុងពង្រឹងសេដ្ឋកិច្ចជាតិ និងសង្គម ជាពិសេសគឺការបន្ថយភាពក្រីក្រនៃប្រជាជាតិទាំងមូល។ ដើម្បីសំរេចបានលទ្ធផលទាំងនេះ រោងចក្រ សហគ្រាស និងសិប្បកម្មជាបឋមចាំបាច់ត្រូវគិតពីធាតុចូលក្នុងខ្សែសង្វាក់ផលិតកម្មរួមមានះ សមត្ថភាពធនធានមនុស្ស សមត្ថភាពម៉ាស៊ីនគ្រឿងចក្រ វត្ថុធាតុដើម ធាតុផ្សំ ទឹក ថាមពល និងបច្ចេកវិទ្យា។ល។ ជាកត្តាចូលរួមនៅក្នុងសកម្មភាពផលិតកម្ម ការកែច្នៃ ដើម្បីទទួលបានផលិតផលសំរេចដែលយើងចង់បាន ដែលជាសមិទ្ធិផលវិជ្ជមាន។ ការពង្រឹងផលិតភាពគុណភាព និងភាពប្រកួតប្រជែងនឹងទទួលជោគជ័យបានគឺអាស្រ័យ

ទៅលើការគ្រប់គ្រងផលិតកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលតាមរយៈគេហកិច្ចល្អ ការប្រើប្រាស់វត្ថុធាតដើម ធាតុផ្សំ ទឹក ថាមពលដោយមានប្រសិទ្ធភាព និងបច្ចេកវិទ្យាល្អប្រសើរ។ ទន្ទឹមនឹងការទទួលបានផលិតផលសំរេច ក៏កើតចេញជាផលអវិជ្ជមានដែលយើងមិនដឹង ឬមិនបានអើពើចំពោះបញ្ហានេះ តាមរយៈការបញ្ចេញកាកសំណល់ រឹង រាវ និងឧស្ម័នទៅក្នុងប្រព័ន្ធបរិស្ថាន ជាផ្នែកមួយបង្កឲ្យមានការប្រែប្រួលអាកាសធាតុ ដែលជាចំណុចកង្វល់របស់សង្គមជាតិទាំងមូលកំពុងប្រឈមនាពេលបច្ចុប្បន្ន និងពេលអនាគត។

ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មជាការចូលរួមចំណែកទទួលខុសត្រូវទាំងបញ្ហាសេដ្ឋកិច្ច សង្គម និងបរិស្ថានដែលជាភារកិច្ច និងសិទ្ធិរបស់យើងគ្រប់រូប ក៏ដូចជាក្រសួងតាមវិស័យ និងសង្គមជាតិទាំងមូល ដើម្បីគិតពិចារណា និងមានវិធានការការពារទុកជាមុនសំរាប់វាស់វែងពីតុល្យភាពដែលអាចទទួលយកបានផលប្រយោជន៍ក្នុងទិដ្ឋភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ក៏ដូចជាបញ្ហាប្រែប្រួលអាកាសធាតុជារួម។

តាមការវិភាគ និងការសិក្សាស្រាវជ្រាវបានពិនិត្យឃើញថាកំណើនឧស្សាហកម្មខ្ពស់នៅឆ្នាំ ២០០៧ ដោយរាប់បញ្ចូលវិស័យវាយនភ័ណ្ឌ កែច្នៃអង្ករ និងសំលៀកបំពាក់ជាផ្នែកមួយនៃវិស័យឧស្សាហកម្មកម្មន្តសាលដែលអាចស្រូបទាញយកផលប្រយោជន៍សេដ្ឋកិច្ចជាតិប្រមាណជាជិតពាក់កណ្តាលនៃតម្លៃបន្ថែមឧស្សាហកម្មទាំងមូល។ ចំនួនរោងចក្រ និងសិប្បកម្មមានការកើនឡើងជាលំដាប់ បើគិតចាប់ពីឆ្នាំ២០០៧ដែលមានចំនួនសរុបប្រមាណ ៣៣,១៨៣ ដែលមានចំនួនកំលាំងពលកម្មសរុបប្រមាណ៥០២,១៦៩នាក់ ហើយកើនជាលំដាប់នៅឆ្នាំ ២០១១ មានចំនួន ៣៨,៣៥៧ រោងចក្រ និងសិប្បកម្ម ដែលអាចស្រូបយកចំនួនកំលាំងពលកម្មសរុបប្រមាណ ៥៩១,១៨៧នាក់ ថ្វីត្បិតតែកំណើនពីមួយឆ្នាំទៅមួយឆ្នាំមិនមានលក្ខណៈថេរក៏ដោយ។ កំណើននៃតម្លៃបរិមាណផលិតផលឧស្សាហកម្មមានកំរិតក្នុងចន្លោះ ២០% ទៅ៣០% ធៀបនឹងផលិតផលជាតិសរុប។ ថ្វីត្បិតតែផលចំណែកនៃផលិតផលជាតិសរុប (GDP) របស់វិស័យឧស្សាហកម្ម មានកំណើនពីប្រមាណ ៥៦% នៅឆ្នាំ ១៩៩៣។

វិស័យកាត់ដេរបានរួមចំណែកដល់ទៅ ៧០% នៃផ្នែកកម្មន្តសាល (១២% នៃ GDP) និងផ្តល់ជាចំណូលប្រមាណ ៧០% នៃចំណូល បានមកពីការនាំចេញរបស់កម្ពុជា។ ក្នុងរយៈពេល ៤ឆ្នាំកន្លងទៅនេះតួលេខ និងកំណើននៃវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យមតាមប្រព័ន្ធចំណាត់ថ្នាក់ឧស្សហកម្មនៃស្តង់ដារអន្តរជាតិ(ISIC)នៅកម្ពុជាបានបង្ហាញនៅក្នុងតារាងទី១និងទី២ ដូចខាងក្រោម៖

តារាងទី១៖ តួលេខរោងចក្រធុនធំដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

| | ប្រភេទឧស្សាហកម្ម | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|
| 31 | ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ (FBT) | 42 | 46 | 53 | 57 |
| 32 | វាយនភ័ណ្ឌ សំលៀកបំពាក់ និងផលិតផលធ្វើពីស្បែក | 418 | 422 | 451 | 537 |
| 33 | ផលិតកម្មកែច្នៃឈើ រួមទាំងគ្រឿងសង្ហារឹម | 6 | 9 | 9 | 9 |
| 34 | ផលិតកម្មក្រដាស ថតចំលង និងបោះពុម្ព | 11 | 11 | 12 | 15 |
| 35 | ផលិតកម្មគីមី ផលិតកម្មគេលសិលាគីមី ធ្យូងថ្ម កៅស៊ូ ផលិតផលប្លាស្ទិក | 32 | 34 | 38 | 47 |
| 36 | ផលិតកម្មក្រៅពីលោហៈ ផលិតផលខនិជ ក្រៅពីប្រេងឥន្ធនៈ និងធ្យូងថ្ម | 9 | 9 | 11 | 12 |
| 37 | ផលិតកម្មដែកសន្លឹក និងលោហៈ | 21 | 22 | 24 | 31 |
| 38 | ផលិតកម្មផ្សេងទៀត | 3 | 3 | 3 | 3 |
| | សរុប | 542 | 556 | 599 | 711 |

តារាងទី២៖ តួលេខសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម បានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

| | សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|
| 31 | ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ (FBT) | 26,208 | 29,987 | 31,479 | 30,513 |
| 32 | វាយនភ័ណ្ឌ សំលៀកបំពាក់ និងផលិតផលធ្វើពីស្បែក | 1,478 | 1,443 | 1,485 | 1,817 |
| 33 | ផលិតកម្មកែច្នៃឈើ រួមទាំងគ្រឿងសង្ហារឹម | - | - | - | 3 |
| 34 | ផលិតកម្មក្រដាស ថតចំលង និងបោះពុម្ព | 43 | 48 | 59 | 62 |
| 35 | ផលិតកម្មគីមី ផលិតកម្មគេលសិលាគីមី ធ្យូងថ្ម កៅស៊ូ និង ផលិតផលប្លាស្ទិក | 192 | 203 | 24 | 241 |
| 36 | ផលិតកម្មក្រៅពីលោហៈ ផលិតផលខនិជ ក្រៅពីប្រេងឥន្ធនៈ និងធ្យូងថ្ម | 875 | 987 | 1,037 | 1,084 |
| 37 | ផលិតកម្មដែកសន្លឹក និងលោហៈ | - | - | - | 4 |
| 38 | លោហៈកម្ម | 3,039 | 1,902 | 2,052 | 2,392 |
| 39 | ផលិតកម្មផ្សេងទៀត | 965 | 990 | 1,086 | 1,530 |
| | សរុប | 32,800 | 35,560 | 37,422 | 37,646 |

### ៥.២. ស្ថានភាពផលិត និងផ្គត់ផ្គង់ថាមពល

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំស្តារឡើងវិញ និងបន្តអភិវឌ្ឍវិស័យថាមពលអគ្គិសនីក្នុងប្រទេស សំរាប់រយៈពេលវែង និងមធ្យមក្នុងទិសដៅពង្រីកការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋទូទាំងប្រទេស។ មកដល់បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានគោលដៅធ្វើយ៉ាងណាអភិវឌ្ឍវិស័យថាមពលប្រើប្រាស់ទូទាំងប្រទេសឲ្យបាន ៨០% នៅឆ្នាំ ២០២០ហើយនៅឆ្នាំ ២០៣០យ៉ាងហោចណាស់ ៧០% នៃគ្រួសារទាំងអស់ទូទាំងប្រទេសកម្ពុជានឹងទទួលបានការប្រើប្រាស់អគ្គិសនីដែលមានគុណភាពដូចអគ្គិសនីពីបណ្តាញបញ្ជូនប្រើប្រាស់។

ដើម្បីឆ្លើយតបនឹងការរីកចំរើនរបស់ប្រទេសជាតិដែលមានតំរូវការថាមពលអគ្គិសនីខ្ពស់ជាមួយអត្រាកំណើនទូទាំងប្រទេសជាមធ្យមចាប់ពីឆ្នាំ ២០០២ ដល់ ២០១១ នេះមានចំនួនប្រមាណ ១៦.៣% ក្នុងមួយឆ្នាំ និងនៅរាជធានីភ្នំពេញមានកំណើនប្រមាណ ១៧% ដែលនេះជាកំណើនមួយដ៏ខ្ពស់បំផុតបើប្រៀបទៅនឹងបណ្តាប្រទេសនានាក្នុងតំបន់។ ដោយកន្លងមក ការផលិតថាមពលស្ទើរតែពឹងផ្អែកទាំងស្រុងលើថាមពលផលិតចេញពីម៉ាស៊ីនភ្លើងដោយប្រើប្រេងម៉ាស៊ូត និងប្រេងខ្មៅប្រមាណជា ៨០% ដែលក្នុងនោះទាំងនៅរាជធានី និងតាមខេត្តបានផលិតអគ្គិសនីដោយម៉ាស៊ីនផ្ទាល់ខ្លួន។ ទើបក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានកសាងស្ថានីយ៍វារីអគ្គិសនីជាបន្តបន្ទាប់ដូចជា៖ កំចាយ តាតៃ និងអាតៃ។ល។ ព្រមទាំងរោងចក្រផលិតអគ្គិសនីដោយប្រើធ្យូងថ្ម និងការតភ្ជាប់បណ្តាញនាំចូលអគ្គិសនីពីប្រទេសជិតខាង ដើម្បីផ្គត់ផ្គង់បំពេញសេចក្តីត្រូវការ និងកំណើននេះ។

## ៦. ផលប៉ះពាល់តាមវិស័យ អនុវិស័យនិងហានិភ័យអាកាសធាតុក្នុងប្រទេសកម្ពុជា

នៅពេលបច្ចុប្បន្ននេះ បញ្ហាប្រែប្រួលអាកាសធាតុត្រូវបានចាប់អារម្មណ៍ទូទាំងសាកលលោក។ ជាពិសេស អ្នកវិទ្យាសាស្ត្របានខិតខំប្រឹងប្រែងស្វែងយល់នូវបាតុភូតនៃការប្រែប្រួលអាកាសធាតុ និងបុព្វហេតុដែលកើតមានឡើង ព្រមទាំងផលប៉ះពាល់នាពេលបច្ចុប្បន្ន និងអនាគតដល់ការរស់នៅរបស់មនុស្សលោក។ ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ណាស់សំរាប់អ្នកសំរេចចិត្តធ្វើគោលនយោបាយ ដោយគេអាចដាក់បញ្ចូលបញ្ហានេះទៅក្នុងបញ្ហាប្រឈម និងរបៀបវារៈនៃកម្មវិធីអភិវឌ្ឍន៍ជាតិ និងសាកលលោក។ ប៉ុន្តែរហូតដល់ពេលនេះ បញ្ហាការប្រែប្រួលអាកាសធាតុនៅតែមានភាពមិនប្រាកដប្រជាដែលធ្វើឲ្យមនុស្សជាតិខិតខំស្វែងយល់នូវភាពស្មុគស្មាញនៃប្រព័ន្ធបរិស្ថានពិភពលោកដូចជាអាកាសធាតុពិភពលោកជាដើម ។

ផ្អែកលើការសិក្សាជាច្រើន និងជាបន្តបន្ទាប់ បានសង្កេតឃើញថាអាកាសធាតុបានប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ហើយភាគច្រើនបំផុតការប្រែប្រួលនេះ ត្រូវបានបង្កឡើងដោយសកម្មភាព និងការរស់នៅរបស់មនុស្ស។ នៅក្នុងនោះ មានការកើនឡើងនូវកំរិតឧស្ម័នកាបូនិក និងឧស្ម័នផ្ទះកញ្ចក់ដ៏ទៃទៀតដែលភាយចេញពីចំហេះប្រេងឥន្ធនៈហ្វូស៊ីល និងការបញ្ចេញចោលទៅក្នុងបរិយាកាសនូវភាគតូចល្អិតផ្សេងទៀតដោយកើតចេញពីផលិតកម្មដូចជាផលិតកម្មស៊ីម៉ង់ត៍ជាដើម។ សកម្មភាពដ៏ទៃទៀតមានដូចជា៖ ការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិតចង្រៃ នៅក្នុងវិស័យកសិកម្ម ការចិញ្ចឹមសត្វ និងការថយចុះនូវបរិមាណព្រៃឈើដោយសារបាតុភូតធម្មជាតិ ការកាប់ព្រៃឈើ និងការបំផ្លាញស្រទាប់អូសូនជាកត្តាដែលបានចូលរួមដោយផ្ទាល់ ដោយប្រយោល ឬទាក់ទងគ្នាទៅវិញទៅមក ហើយបានជះឥទ្ធិពលទៅលើអាកាសធាតុ។

តាមការអង្កេតការប្រើប្រាស់ថាមពលក្នុងការកែច្នៃកៅស៊ូឃើញថាខ្ពស់ជាង២ដង ប្រសិនបើធៀបនឹងកំរិតស្តង់ដារអន្តរជាតិ។ រីឯក្នុងវិស័យកែច្នៃអង្ករ ក៏មានកំរិតខ្ពស់ជាង ៣០% បើធៀបនឹងស្តង់ដារអន្តរជាតិ ក៏ដូចជាក្នុងវិស័យវាយនភ័ណ្ឌ និងឡឥដ្ឋក៏ដូច្នោះដែរ។ យើងពិនិត្យឃើញថាឧស្សាហកម្មកម្មន្តសាលបានមានតំរូវការប្រើប្រាស់ប្រេងម៉ាស៊ូត និងឥន្ទនៈផ្សេងៗយ៉ាងច្រើនដូចជា៖ ឧស្សាហកម្មវាយនភ័ណ្ឌ និងកែច្នៃម្ហូបអាហារ ចំណែកឡឥដ្ឋក៏មានការប្រើប្រាស់ថាមពល ដោយប្រើប្រាស់អុសដែលជាបញ្ហានាំឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការបំពុលដល់បរិស្ថាន។ បញ្ហាទាំងនេះ អាចមានជំរើសច្រើនក្នុងការកាត់បន្ថយការបំភាយជាតិពុលបតាមរយៈការអនុវត្តន៍ការសន្សំសំចៃថាមពល និងផ្លាស់ប្តូរបច្ចេកវិទ្យាដែលមានលក្ខណៈបរិស្ថាន។

## ៧. គោលនយោបាយ និងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបាននឹងកំពុងផ្តោតលើការកសាងគោលនយោបាយ និងផែនការអភិវឌ្ឍន៍វិស័យថាមពលដែលជាយន្តការណ៍ដ៏សំខាន់ក្នុងការអភិវឌ្ឍន៍វិស័យផ្សេងៗទៀត នៅក្នុងប្រទេសលើការផ្ទេរបច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល។ ស្ថាប័ននេះនឹងក្លាយជាតួអង្គកាន់តែសំខាន់ថែមទៀត ក្នុងយុទ្ធសាស្ត្រសំរាប់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់តាមរយៈការកសាងគោលនយោបាយ ប្រសិទ្ធភាពថាមពល បទបញ្ញត្តិ បទដ្ឋានបច្ចេកទេស ការពង្រឹង និងពង្រីកស្ថាប័នកិច្ច និងសមត្ថភាពមន្ត្រីលើប្រធានបទថាមពល និងឧស្សាហកម្មបៃតង ការផ្ទេរថាមពលកកើតឡើងវិញ។

តាមរយៈគោលនយោបាយយុទ្ធសាស្ត្រ និងរបាយការណ៍លើកកំពស់ចំណេះដឹង និងការអប់រំការអង្កេត ការវាយតម្លៃតំរូវការសំរាប់ការបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ ការវាយតម្លៃគម្លាតចំណេះដឹង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនឹងពិនិត្យឡើងវិញតាមអន្តរវិស័យគួរឲ្យចាប់អារម្មណ៍នូវគម្លាតចំណេះដឹងតាមស្ថាប័នរដ្ឋ គ្រឹះស្ថានសិក្សា និងប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ ដើម្បីគាំទ្រដល់ចក្ខុវិស័យនៃការកែសំរួលឡើងវិញនូវរចនាសម្ព័ន្ធប្រព័ន្ធនៃការគ្រប់គ្រងចំណេះដឹង និងការលើកកំពស់ចំណេះដឹងជាទូទៅស្តីអំពីការប្រែប្រួលអាកាសធាតុ។

### ៧.១. វិស័យឧស្សាហកម្ម

#### ក. ប្រសិទ្ធភាពថាមពលក្នុងវិស័យឧស្សាហកម្ម

ប្រសិទ្ធភាពថាមពលត្រូវបានគេហៅថាជាថាមពលទី ៥បន្ទាប់ពីប្រេង ធ្យូងថ្ម ឧស្ម័ន និងថាមពលកកើតឡើងវិញដែលនឹងចូលរួមដោះស្រាយនូវបញ្ហាការប្រែប្រួលអាកាសធាតុ និងសន្តិសុខថាមពល។ អ្នកវិភាគជាច្រើនបានទទួលស្គាល់ថាប្រសិទ្ធភាពថាមពលជាឧបករណ៍មួយដែលមានសក្តានុពលដ៏ធំក្នុងការបង្ហាញឡើងនូវគោលដៅជាមូលដ្ឋាននៃគោលនយោបាយថាមពលរបស់ប្រទេសលើសាកលលោកគឺ៖ ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច សន្តិសុខ ថាមពល និងចីរភាពបរិស្ថាន។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនរួមទាំងកម្ពុជាពុំទាន់មានលទ្ធភាពពេញលេញ នៅក្នុងការទទួលបាននូវប្រភពថាមពលជំនួសឲ្យការប្រើប្រាស់ឥន្ទនៈហ្វូស៊ីល(ប្រេងឥន្ទនៈ) ប្រសិទ្ធភាពថាមពល រួមមានការសន្សំសំចៃថាមពល និងការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព គឺជាដំណោះស្រាយដ៏ប្រសើរបំផុតសំរាប់កម្ពុជាកំពុងត្រូវបានជំរុញ និងមានការយកចិត្តទុកដាក់ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាក្នុងការ

កាត់បន្ថយការបំភាយចេញនូវឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុទៀតផង។

នៅក្នុងវិស័យឧស្សាហកម្មកម្ពុជាមានការចំណាយធំៗបីយ៉ាង ទៅលើកិច្ចដំណើរការផលិតកម្មដែលរួមមាន៖ ថាមពល (គិតរួមទាំងថាមពលអគ្គិសនី និងថាមពលកំដៅ) កំលាំងពលកម្ម និងវត្ថុធាតុដើម។ នៅក្នុងការចំណាយធំៗទាំងបីខាងលើថាមពល គឺជាចំណុចដែលមានសក្តានុពលបំផុតក្នុងការរួមចំណែកនៃការកាត់បន្ថយការចំណាយសំរាប់កិច្ចដំណើរការផលិតកម្មនៅកម្ពុជា។ ដូចនេះប្រសិទ្ធភាពថាមពលនឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីគោលនយោបាយ និងផែនការសកម្មភាពនៃដំណើរការផលិតកម្មក្នុងប្រភេទរោងចក្រ សហគ្រាស និងសិប្បកម្មដូចខាងក្រោម៖

- ផលិតកម្មចំណីអាហារ
- ផលិតកម្មកិនស្រូវ និងការកែច្នៃអង្ករ
- វិស័យកាត់ដេរសំលៀកបំពាក់ និងការផលិតសំលៀកបំពាក់ចាក់
- ផលិតកម្មឡឥដ្ឋ និងក្បឿង
- ផលិតកម្មក្រដាសជាដើម

**ខ. ឧស្សាហកម្មបៃតង** ( Green Industry )

ឧស្សហកម្មបៃតង គឺជាផលិតកម្មឧស្សាហកម្ម និងការអភិវឌ្ឍន៍ឧស្សាហកម្មដែលពុំបានផ្តល់ប៉ះពាល់ផលជាអវិជ្ជមានដល់ប្រព័ន្ធធម្មជាតិ ឬសុខភាពមនុស្ស និងការចូលរួមចំណែកក្នុងបញ្ហាការប្រែប្រួលអាកាសធាតុ ការងារបរិស្ថាន និងការងារសង្គមទៅក្នុងប្រតិបត្តិការរបស់រោងចក្រ សហគ្រាស និងសិប្បកម្ម។ ឧស្សាហកម្មបៃតងក៏ផ្តល់នូវមូលដ្ឋានក្នុងការបង្ហាញឡើងនូវបញ្ហាប្រឈមដែលមានលក្ខណ:សាកល និងទាក់ទងគ្នាទៅវិញទៅមកតាមរយ:វិធីសាស្ត្រប្រទាក់ក្រឡាគ្នាយ៉ាងសកម្ម និងទាន់ពេលវេលា ព្រមទាំងយុទ្ធសាស្ត្រទាំងឡាយដែលអាចទាញយកប្រយោជន៍ពីឧស្សាហកម្មថ្មីៗ និងពីឥទ្ធិពលទីផ្សារ។ លើសពីនេះទៀត ឧស្សាហកម្មបៃតងជាចលករជំរុញការអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ផងដែរ ព្រមទាំងជួយលើកទឹកចិត្តដល់វិស័យនវានុវត្តន៍ ពោលគឺបង្កើតនូវកាលានុវត្តន៍ភាពនៃធុរ:កិច្ច និងការងារថ្មីៗដែលនឹងរួមចំណែកយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ និងការជំរុញឧស្សហកម្មបៃតងរួមមាន៖

- ការធ្វើឲ្យមានបៃតងចំពោះឧស្សាហកម្មដែលមានស្រាប់
- និងការបង្កើតឧស្សាហកម្មបៃតង។

- **ការធ្វើឲ្យមានបៃតងភាពចំពោះឧស្សាហកម្មដែលមានស្រាប់**

ការធ្វើឲ្យមានភាពបៃតងចំពោះវិស័យឧស្សាហកម្មដែលមានស្រាប់ គឺធ្វើឲ្យប្រសើរឡើងប្រកបដោយនិរន្តភាពនូវផលិតភាពធនធាន និងកិច្ចប្រតិបត្តិការណាដែលមានការគិតគូរដល់បរិស្ថានសំរាប់គ្រប់ឧស្សាហកម្មទាំងអស់ ដោយទាមទារឲ្យមានការប្តេជ្ញាចិត្ត និងធ្វើសកម្មភាពក្នុងការកាត់បន្ថយផលប៉ះពាល់ផ្នែកបរិស្ថានតាមរយ:

– ការលើកកំពស់ប្រសិទ្ធភាពផលិតកម្មដោយប្រើប្រាស់ធនធានឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន និងកាត់បន្ថយឲ្យតិចបំផុតតាមភាពចាំបាច់នូវការប្រើប្រាស់ធនធានដូចជា៖

១). ប្រើប្រាស់សារធាតុ ឬសំណល់ដែលអាចធ្វើការកែច្នៃឡើងវិញបានធ្វើជាវត្ថុធាតុដើម ឬមុខចូលផលិតកម្មជំនួសឲ្យការប្រើប្រាស់សារធាតុដែលពុំអាចកែច្នៃបាន ឬប្រើប្រាស់សារធាតុដែលមានវដ្តនៃជីវិតធន់នឹងការប្រើប្រាស់បានយូរ

២). ប្រើប្រាស់វិធីសាស្ត្រ ការប្រើប្រាស់ឡើងវិញ ការកាត់បន្ថយ និងការកែច្នៃប្រើប្រាស់ឡើងវិញ (3Rs: Reuse, Reduce and Recycle) នៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម។

– ការពង្រឹងកិច្ចប្រតិបត្តិដែលមានការគិតគូរដល់បរិស្ថានដូចជា៖

១). ការកាត់បន្ថយនូវផលប៉ះពាល់ដល់បរិស្ថាន ដោយកាត់បន្ថយដំណើរការផលិតកម្មដែលបង្កើត បញ្ចេញចោល ឬបំភាយចេញនូវកាកសំណល់ឧស្សាហកម្ម ឬធ្វើឲ្យប្រសើរឡើងនូវដំណើរការផលិតកម្ម ដោយមានការថែទាំ និងត្រួតពិនិត្យសុវត្ថិភាពផលិតកម្មបានត្រឹមត្រូវ

២). ការប្រើប្រាស់បច្ចេកវិទ្យាដែលមានឧត្តមភាព និងមានប្រសិទ្ធភាពខ្ពស់

៣). ការគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាពបរិស្ថាន ដោយលើកកំពស់ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ ការគ្រប់គ្រងសំណល់សារធាតុគីមីគ្រោះថ្នាក់ឲ្យបានត្រឹមត្រូវ និងការប្រើប្រាស់ឡដុតសំណល់ដែលមានប្រសិទ្ធភាព និងបច្ចេកវិទ្យាខ្ពស់។

– ការកាត់បន្ថយហានិភ័យនៃការប្រឈមនឹងសារធាតុគ្រោះថ្នាក់ និងសំណល់សារធាតុគ្រោះថ្នាក់ដូចជា៖

១). ការប្រើប្រាស់សារធាតុជំនួសដែលមានជាតិពុល ឬហានិភ័យតិច

២). ការប្រើប្រាស់បច្ចេកវិទ្យាដ៏ប្រសើរ និងការអនុវត្តន៍បរិស្ថានដ៏ប្រសើរសំរាប់ការកាត់បន្ថយ និងរារាំងនូវការបង្កើតឡើងដោយអចេតនាក្នុងផលិតកម្មនូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ និងអនុផលផ្សេងទៀតដែលបង្កហានិភ័យដល់សុខភាព សុវត្ថិភាព និងបរិស្ថាន

៣). ដំណើរការផលិតកម្មដែលមានសារធាតុគីមីដោយប្រើប្រាស់ជំនួសនូវដំណើរការផលិតកម្មមិនមានសារធាតុគីមីដែលមានដូចជា៖ ដំណើរការជីវសាស្ត្រ និងរូបសាស្ត្រជាដើម។

- **ការបង្កើតឧស្សាហកម្មបៃតង**

ឧស្សាហកម្មបៃតង គឺជាការជំរុញជាលក្ខណៈប្រព័ន្ធក្នុងការបង្កើត និងពង្រីកវិសាលភាពឧស្សាហកម្មបៃតងសំខាន់ៗដែលនឹងផ្តល់នូវទំនិញ និងសេវាកម្មប្រកបដោយសុវត្ថិភាពបរិស្ថានគិតចាប់ពី៖ ផលិតកម្មកម្មន្តសាល ការបំពាក់នូវថាមពលកកើតឡើងវិញ និងរហូតដល់ការអភិវឌ្ឍន៍បច្ចេកវិទ្យាស្អាត ព្រមទាំងផ្នែកសេវាកម្មផ្សេងៗរួមមាន៖ ក្រុមហ៊ុនដែលទាញយកវត្ថុធាតុដើមឡើងវិញ ក្រុមហ៊ុនកែច្នៃឡើងវិញ និងក្រុមហ៊ុនគ្រប់គ្រងសំណល់ និងធ្វើប្រព្រឹត្តិកម្មសំណល់។ ដើម្បីផ្តល់នូវដំណោះស្រាយបញ្ហាទាំងអស់នេះ ឧស្សាហកម្មបៃតងក៏គិតរួមបញ្ចូលនូវការប្រឹក្សាអំពីបរិស្ថាន និងថាមពលផងដែរ។

តាមបទពិសោធន៍ជាច្រើនរួមមាន៖ ការអភិវឌ្ឍន៍ឧស្សាហកម្មថ្មីៗ ការបង្កើននូវប្រសិទ្ធភាពឧស្សាហកម្មដែលមានស្រាប់ និងឥទ្ធិពលនៃឧស្សាហកម្មបៃតងបានបង្ហាញនូវកាលានុវត្តន៍ភាព និងអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងសំខាន់ជាពិសេសសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មបៃតងបង្ហាញចេញនូវអត្ថប្រយោជន៍នៅក្នុងសកម្មភាព ៣យ៉ាងគឺ៖ អត្ថប្រយោជន៍សេដ្ឋកិច្ច អត្ថប្រយោជន៍បរិស្ថាន និងអត្ថប្រយោជន៍សង្គម។

ជាមួយគ្នានេះ ឧស្សាហកម្មបៃតងក៏បានបង្ហាញកាលានុវត្តភាព ក្នុងការជំនះនូវបញ្ហាបរិស្ថានពីរយ៉ាងគឺការប្រែប្រួលអាកាសធាតុ និងការបំពុលដោយសារធាតុគីមី។ ឧស្សហកម្មបៃតងជាតិនៅកម្ពុជាបានផ្សារភ្ជាប់ទៅនឹងបរិបទនៃការអភិវឌ្ឍន៍បៃតងជាតិហើយ នឹងដើរតួយ៉ាងសំខាន់មួយក្នុងការរួមវិភាគទាននៃការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្មកម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យមទៅក្នុងកំណើនចំណូលផលិតផលសរុបក្នុងស្រុក ក៏ដូចជាកំណើនចំណូលផលិតផលសរុបរបស់ជាតិ ។

**គ. ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកំណត់ចំណុចបំពុលខ្លាំង និងការផ្ទេរបច្ចេកវិទ្យាអំណោយផលដល់បរិស្ថាន** ( Hot-Spot & TEST )

គោលបំណងនៃការផ្ទេរបច្ចេកវិទ្យានេះ គឺជួយដោះស្រាយបញ្ហាការបំពុលខ្លាំងចេញពីរោងចក្រសហគ្រាស សិប្បកម្មមួយចំនួន សំដៅទប់ស្កាត់ការពារនឹងការប្រែប្រួលអាកាសធាតុ និងលើកស្ទួយការអភិវឌ្ឍន៍បៃតងក្នុងប្រទេស។ ការផ្ទេរបច្ចេកវិទ្យានេះ ធ្វើឡើងតាមរយៈវិធីសាស្ត្រដូចខាងក្រោម៖

- **វិធីសាស្ត្រវាយតម្លៃចំណុចបំពុលខ្លាំង Hot-Spot:**

  ១). ការវាយតម្លៃបឋម

  ២). ការវាយតម្លៃលំអិតដោយផ្អែកលើកត្តា៖ ជីវៈចំរុះ គ្រប់គ្រងការបំពុល សេដ្ឋកិច្ចសង្គម និង គុណភាពទឹក។

  ៣). ការកំណត់អាទិភាពចំណុចបំពុល

- **វិធីសាស្ត្រនៃការផ្ទេរបច្ចេកវិទ្យាអំណោយផលដល់បរិស្ថាន (TEST-Transfer of Environmentally Sound Technologies)**

វិធីសាស្ត្រនៃការផ្ទេរបច្ចេកវិទ្យាអំណោយផលដល់បរិស្ថាន គឺជាវិធីសាស្ត្រនៃការរួមបញ្ចូលគ្នារវាងផលិតកម្មស្អាត គណនេយ្យភាពគ្រប់គ្រងបរិស្ថាន ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងការទទួលខុសត្រូវរួមគ្នាចំពោះសង្គម។

❖ **ការវាយតម្លៃ និងការអនុវត្តន៍ផលិតកម្មស្អាត (Cleaner Production- CP)**

ផលិតកម្មស្អាត និងប្រសិទ្ធភាពធនធាន គឺទស្សនៈទានមួយយ៉ាងទូលំទូលាយផ្តោតមិនត្រឹមតែលក្ខណៈបច្ចេកទេសគឺ៖ កត្តាសង្គម កត្តាសេដ្ឋកិច្ច និងកត្តាបរិស្ថានផងដែរ ដោយមានលក្ខណៈវិភាគស៊ីជំរៅទៅលើការអនុវត្តន៍ ការការពារបរិស្ថាន ការគ្រប់គ្រងផលិតភាពសរុប វិធីសាស្ត្រត្រូវបានប្រើនៅក្នុងសហគ្រាស សេវាកម្ម និងផលិតកម្មផងដែរ ដើម្បីធ្វើឲ្យប្រសើរឡើងការប្រើប្រាស់វត្ថុធាតុដើម ទឹក និងថាមពល ការកាត់បន្ថយការកកើតឡើងនៃឧស្ម័នផ្ទះកញ្ចក់ និងការបំភាយឧស្ម័នពុលផ្សេងៗ ព្រមទាំងសំណល់ ការការពារ និងការកាត់បន្ថយ ហានិភ័យផ្នែកសុវត្ថិភាព និងសុខភាពមនុស្សទូទៅ។

❖ **គណនេយ្យភាពនៃការគ្រប់គ្រងបរិស្ថាន (Environmental Management Accounting-EMA)**

គណនេយ្យភាពនៃការគ្រប់គ្រងបរិស្ថានផ្តោតសំខាន់លើវត្ថុធាតុ និងការចំណាយ៖ ការប្រើប្រាស់ថាមពល ទឹក និងវត្ថុធាតុ ក៏ដូចជាការបញ្ចេញសំណល់ និងការបំភាយឧស្ម័ន គឺសុទ្ធតែពាក់ព័ន្ធការប៉ះពាល់ដល់បរិស្ថាន និងផលិតផលរបស់ខ្លួន ហើយការចំណាយលើវត្ថុធាតុ និងការបាត់បង់វត្ថុធាតុទៅតាមសំណល់ និងការបំភាយគឺជាចំណាយដែលអាចឃើញជាក់ស្តែងបំផុតតាមរយៈការកត់ត្រា។

❖ **ប្រព័ន្ធគ្រប់គ្រងបរិស្ថាន (Environmental Management System-EMS)**

ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ជាវិធីសាស្ត្រដែលប្រចាប់បញ្ចូលគ្នានូវគោលដៅថាមពល និងបរិស្ថាន និងការកំណត់អាទិភាព(ដូចជាការប្រើប្រាស់ថាមពល និងភាពអនុលោមតាមច្បាប់) ឲ្យក្លាយទៅជាការប្រតិបត្តិប្រចាំថ្ងៃ។ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ជាប្រព័ន្ធមួយដែលមានទំនាក់ទំនងគ្នារវាងផ្នែកគោលនយោបាយបរិស្ថាន ផែនការ ការអនុវត្តន៍ និងការប្រតិបត្តិ ការត្រួតពិនិត្យ និងវិធានការកែតំរូវ ការត្រួតពិនិត្យឡើងវិញនៃការគ្រប់គ្រងដែលផ្នែកទាំងអស់នេះ គឺមានគោលបំណងគ្រប់គ្រងរាល់សកម្មភាពដែលមាន ឬអាចមានផលប៉ះពាល់ដល់បរិស្ថាន ហើយដែលផ្តល់ផលប្រយោជន៍ដល់រោងចក្រ សហគ្រាស និងសិប្បកម្មក្នុងការគិតគូរពីបរិស្ថាន ការសំរេចចិត្តលើអ្វីដែលខ្លួនចង់ធ្វើការដឹងពីរបៀបអនុវត្ត ការអនុវត្តន៍តាមអ្វីដែលបានគ្រោងទុក ការកែតំរូវនូវអ្វីដែលមានគម្លាតពីផែនការ និងការពិនិត្យឡើងវិញលើផែនការសំរាប់ទិសដៅ ដើម្បីអនុវត្តបន្តឲ្យលទ្ធផលប្រសើរឡើង នាពេលអនាគត។

❖ **ការទទួលខុសត្រូវរួមគ្នាចំពោះសង្គម (Corporate Social Responsibility-CSR)**

ការទទួលខុសត្រូវរួមគ្នាចំពោះសង្គម ជាការទទួលខុសត្រូវរបស់សហគ្រាសលើឥទ្ធិពលដែលកើតចេញពីការសំរេចចិត្ត និងសកម្មភាពនានា ចំពោះសង្គម និងបរិស្ថានតាមរយៈការអនុវត្តន៍ប្រកបដោយតម្លាភាព និងក្រមសីលធម៌ វិជ្ជាជីវៈរួមមាន៖

- ភាពស្របគ្នានឹងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព និងសុខមាលភាពសង្គម
- គិតគូរតាមការរំពឹងទុករបស់ភាគីពាក់ព័ន្ធ
- ភាពអនុលោមតាមច្បាប់ និងស្តង់ដារអន្តរជាតិ
- ភាពច្របាច់បញ្ចូលលើគ្រប់ដំណោះស្រាយទៅក្នុងសហគ្រាសទាំងមូលនិងភាគីពាក់ព័ន្ធ

ការទទួលខុសត្រូវរួមគ្នាចំពោះសង្គមដែលត្រូវគិតគូរដល់តុល្យភាពនៃលក្ខណៈវិនិច្ឆ័យលើកត្តាសេដ្ឋកិច្ច សង្គម និងបរិស្ថានរួមមាន៖ ការអភិបាលកិច្ចសហគ្រាស សិទ្ធិមនុស្ស ទម្លាប់អនុវត្តការងារ ការងារបរិស្ថាន ការអនុវត្តន៍ប្រតិបត្តិស្មើភាព បញ្ហាអតិថិជន និងការអភិវឌ្ឍន៍សង្គម (ការចូលរួមពីសហគមន៍ និងការអភិវឌ្ឍន៍សហគមន៍)។

### ឃ. ការគ្រប់គ្រងសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម

ថ្វីត្បិតតែប្រទេសកម្ពុជាពុំមែនជាប្រទេសឧស្សាហកម្មជឿនលឿនក៏ពិតមែន ប៉ុន្តែដំណើរការឧស្សាហកម្ម នៅកម្ពុជាមានការរីកចំរើនជាលំដាប់ ដែលរោងចក្រ សហគ្រាស និង សិប្បកម្មភាគច្រើនបាននាំចូលទាំងស្រុងពីបរទេសនូវសារធាតុគីមីជាវត្ថុធាតុដើម និងជាសារធាតុផ្សំសំរាប់ដំណើរការផលិតកម្ម ហើយសារធាតុគីមីទាំងនោះត្រូវបានបែងចែកជាច្រើនប្រភេទក្នុងគោលដៅខុសៗគ្នាដូចជា៖ ប្រភេទសារធាតុគីមីសរីរាង្គ ប្រភេទសារធាតុគីមីអសរីរាង្គ ប្រភេទសារធាតុគីមីជ្រលក់ពណ៌ និងប្រភេទសារធាតុគីមីសំរាប់ធ្វើប្រព្រឹត្តកម្មសំអាត និងគោលដៅប្រើប្រាស់ផ្សេងៗទៀត។ ចំណែកព័ត៌មានទិន្នន័យទាក់ទងនឹងការនាំចូលសារធាតុគីមីជាវត្ថុធាតុដើមបំរើដល់វិស័យឧស្សាហកម្ម និងសហគ្រាសធុនតូចមធ្យម និងសិប្បកម្មត្រូវបានពិនិត្យ និងកំណត់ត្រា នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម) ។

ទន្ទឹមនឹងការផ្តល់សារៈប្រយោជន៍នៃការប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម គឺមានសារធាតុគីមីមួយចំនួនធំបានបង្កផលប៉ះពាល់ជាអវិជ្ជមានទៅលើ បរិស្ថាន និងសុខភាពសាធារណៈ

តាមរយៈការបំភាយចេញជាឧស្ម័នពុល ឧស្ម័នដែលប៉ះពាល់ដល់ស្រទាប់បរិយាកាស និងតាមរយៈការបញ្ចេញសំណល់រឹង និងរាវគ្រប់ប្រភេទដែលជាលទ្ធផលបានធ្វើឲ្យខាតបង់ថវិកាជាតិយ៉ាងច្រើនដូចនេះ តំរូវឲ្យមានការដោះស្រាយឲ្យបានម៉ត់ចត់ និងការទទួលខុសត្រូវខ្ពស់សំរាប់ ការប្រើប្រាស់ និងការគ្រប់គ្រងសារធាតុគីមីជាបញ្ហាប្រឈមដ៏ធំមួយត្រូវយកចិត្តទុកដាក់ទុកជាមុនដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

## ៧.២. ការអភិវឌ្ឍន៍វិស័យថាមពល

### ក. គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល

ថាមពលអគ្គិសនី គឺជាវិស័យអាទិភាពមួយដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍន៍ ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ពីព្រោះថាមពលអគ្គិសនីមិនមែនត្រូវការចំបាច់តែសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់រូប ប៉ុណ្ណោះទេ ប៉ុន្តែថាមពលអគ្គិសនីក៏មានសារៈសំខាន់ចំពោះការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម កសិកម្ម និងវិស័យផ្សេងៗទៀត ដើម្បីការរីកចំរើនផ្នែកសេដ្ឋកិច្ចផងដែរ។ គោលដៅសំខាន់នៃការអភិវឌ្ឍន៍វិស័យអគ្គិសនីនៅក្នុងប្រទេសកម្ពុជាគឺធ្វើយ៉ាងណាឲ្យមានការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់សំរាប់ប្រើប្រាស់នៅទូទាំងប្រទេសក្នុងតម្លៃមួយសមរម្យ ហើយធ្វើឲ្យការផលិត ការផ្គត់ផ្គង់ និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តទៅប្រកបដោយគុណភាព ប្រសិទ្ធភាព ចីរភាព និងតម្លាភាព ដើម្បីសំរួលដល់ការវិនិយោគ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូល។

ក្នុងបរិបទនេះចំពោះការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី រាជរដ្ឋាភិបាលកម្ពុជាក៏បានជំរុញការអភិវឌ្ឍន៍ប្រភពថាមពលនានាដែលមានផលប៉ះពាល់តិចតួចដល់បរិស្ថាន និងប្រកបដោយនិរន្តភាពផងដែរ តាមរយៈការវិនិយោគលើស្ថានីយ៍ផលិតថាមពលអគ្គិសនីដែលប្រើប្រាស់ប្រភពថាមពលដែលមានក្នុងស្រុកដូចជា៖ វារីអគ្គិសនី ឧស្ម័នធម្មជាតិ ធ្យូងថ្ម ជីវៈម៉ាស ជីវៈឧស្ម័ន ពន្លឺព្រះអាទិត្យ និងប្រភពថាមពលនាំចូលដែលអាចទុកចិត្តបានសំរាប់រយៈពេលវែង និងបន្តនាំចូលអគ្គិសនីពីប្រទេសជិតខាង ដើម្បីឲ្យកម្ពុជាមានប្រភពថាមពលអគ្គិសនីសំរាប់ផ្គត់ផ្គង់គ្រប់គ្រាន់។

- **ក្នុងរយៈពេលកន្លងមក ការអភិវឌ្ឍន៍ថាមពលអគ្គិសនីនៅ ព្រះរាជាណាចក្រកម្ពុជាមានវឌ្ឍនភាពគួរឲ្យកត់សំគាល់ដែលសំរេចបានរួមមាន៖**

១). ការស្តារ និងពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅក្នុងរាជធានីភ្នំពេញ តាមបណ្តាខេត្តក្រុង និងទីប្រជុំជននានា

២). ការនាំចូលអគ្គិសនី តាមរូបភាពតូចៗពីប្រទេសជិតខាង ដើម្បីផ្គត់ផ្គង់ក្នុងទីប្រជុំជន និងតំបន់ក្បែរព្រំដែន

៣). ការរៀបចំបណ្តាញផ្គត់ផ្គង់អគ្គិសនីតូចៗ ដោយប្រើប្រាស់ម៉ាស៊ីនភ្លើងដែលប្រើប្រេងម៉ាស៊ូត និងថាមពលកកើតឡើងវិញ ដើម្បីផ្គត់ផ្គង់អគ្គិសនីតាមតំបន់ជនបទនានា។

- **រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយថាមពលដូចខាងក្រោម៖**

១). ផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់នៅក្នុងទូទាំងប្រទេសតាមតម្លៃសមរម្យ

២). ធានាឲ្យមានការទុកចិត្ត និងស្ថេរភាពក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីសំរួលដល់ការវិនិយោគ និងការអភិវឌ្ឍន៍សេដ្ឋជាតិ

៣). លើកទឹកចិត្តការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍ធនធានថាមពលមិនប៉ះពាល់ ឬប៉ះពាល់តិចតួចដល់បរិស្ថាន និងសង្គម

៤). លើកទឹកចិត្តការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយការប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពល។

- **យុទ្ធសាស្ត្រក្នុងការបង្កើនសន្តិសុខថាមពលរួមមាន៖**
  - ជំរុញបង្កើនការអភិវឌ្ឍន៍ប្រភពថាមពលអគ្គិសនីដែលមានក្នុងស្រុក ជាពិសេសវារីអគ្គិសនី និងការប្រើប្រាស់ឲ្យមានប្រសិទ្ធភាពខ្ពស់
  - ជំរុញពិពិធកម្មប្រភពថាមពលអគ្គិសនីច្រើនប្រភេទ
  - ជំរុញ និងលើកទឹកចិត្តការវិនិយោគផ្គត់ផ្គង់អគ្គិសនីពីផ្នែកឯកជន
  - ជំរុញពាណិជ្ជកម្មអគ្គិសនីក្នុងតំបន់តាមរយៈសហប្រតិបត្តិការទ្វេរភាគី និងពហុភាគី និង
  - ធានាសន្តិសុខថាមពលដោយបង្កើតឲ្យមានប្រភពថាមពលបំរុងនៅក្នុងស្រុក។

ការអភិវឌ្ឍន៍វិស័យថាមពល រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិ និងរៀបចំផែនការមេសំរាប់ធ្វើជាត្រីវិស័យក្នុងការអភិវឌ្ឍន៍ឲ្យមានប្រសិទ្ធភាព រួមទាំងបានរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពល ដើម្បីបង្កើនសន្តិសុខថាមពលសំរាប់ប្រទេស និងជាពិសេសគោលនយោបាយជាតិស្តីពីអគ្គិសនីភាវូបនីយកម្មជនបទកម្ពុជា នៅក្នុងគោលបំណងចូលរួមអភិវឌ្ឍតំបន់ជនបទ និងកាត់បន្ថយភាពក្រីក្រ និងបង្កើនសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាជន នៅតាមតំបន់ជនបទ។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទបន្ថែមទៀតទាំងការពង្រីកបណ្តាញអគ្គិសនីចេញពីបណ្តាញបញ្ជូនជាតិ និងចេញពីតំបន់ដែលមានប្រភពអគ្គិសនីមានតម្លៃថោកនានា រួមទាំងការអភិវឌ្ឍន៍ការផ្គត់ផ្គង់អគ្គិសនីដោយថាមពលកកើតឡើងវិញ ធ្វើយ៉ាងណាឲ្យប្រជាជននៅតំបន់ជនបទទាំងអស់ទទួលបានអគ្គិសនីប្រើប្រាស់។

### ខ. ការអភិវឌ្ឍន៍វិស័យថាមពលដែលអំណោយផលដល់បរិស្ថាន

គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល ក៏បានយកចិត្តទុកដាក់ជាចំបងលើបញ្ហាផលប៉ះពាល់បរិស្ថានដូចជា៖

- **អគ្គិសនីភាវូបនីយកម្មជនបទ**

រាជរដ្ឋាភិបាលក៏បានបង្កើតស្ថាប័នមួយហៅថាអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បី៖

១) ជំរុញឲ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ជួយឲ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃដែលអាចជាវបានដែលជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ

២) ជំរុញលើកទឹកចិត្តឲ្យអ្នកវិនិយោគធ្វើសេវាកម្មអគ្គិសនី នៅតាមជនបទប្រកបដោយចីរភាពតាមរយៈការអនុវត្តន៍បច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញ។

- **ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យប្រភេទលំនៅដ្ឋាន**

គោលបំណងនៃការអនុវត្តន៍ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ គឺដើម្បីលើកទឹកចិត្តដល់ក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ព្រមទាំងកាត់បន្ថយថ្លៃដើមនៃប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យប្រភេទលំនៅដ្ឋានតាមរយៈគម្រោងមូលនិធិអគ្គិសនីជនបទ នៅក្នុងការសំរួលដល់គ្រួសារតាមជនបទអាចមានលទ្ធភាពទិញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យប្រភេទលំនៅដ្ឋាន និងជួយសំរួលឲ្យគ្រួសារតាម

ជនបទទាំងអស់នោះអាចទទួលបានអគ្គិសនីប្រើប្រាស់ នៅកន្លែងដែលខ្សែបណ្តាញអគ្គិសនីពុំទាន់ទៅដល់។

- **រោងចក្រវារីអគ្គិសនីខ្នាតតូច ខ្នាតមធ្យមនិងរោងចក្រអគ្គិសនីដើរដោយថាមពលកកើតឡើងវិញ**

គោលបំណងនៃការបង្កើតរោងចក្រវារីអគ្គិសនីខ្នាតតូច ខ្នាតមធ្យម និងរោងចក្រអគ្គិសនីដើរដោយថាមពលកកើតឡើងវិញ គឺដើម្បីជំរុញដល់ការអភិវឌ្ឍន៍រោងចក្រអគ្គិសនីប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងផ្គត់ផ្គង់អគ្គិសនីដល់គ្រួសារជនបទ។

ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលក៏បាននឹងកំពុងជំរុញឲ្យមានប្រភពថាមពលអគ្គិសនីប្រើប្រាស់ជីវៈម៉ាស់ ថាមពលពន្លឺព្រះអាទិត្យ ថាមពលជីវៈឧស្ម័ន នៅតាមតំបន់ជនបទជាច្រើនកន្លែងទៀត ដើម្បីឲ្យមានថាមពលប្រើប្រាស់ដល់មូលដ្ឋានឆ្ងាយៗ។ ក្នុងគោលដៅដើម្បីកាត់បន្ថយការប្រើប្រាស់អុសធ្យូងនៅកម្ពុជា ហើយក្រសួងក៏បានរៀបចំឲ្យមានការសិក្សា និងការណែនាំឲ្យប្រើប្រាស់ចង្ក្រានដែលមានប្រសិទ្ធភាព។ ទាំងនេះជាការចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

## ៨. វិធានការឆ្លើយតបតាមវិស័យដែលមានស្រាប់ និងអាចអនុវត្តបានចំពោះការប្រែប្រួលអាកាសធាតុ

### ៨.១. ចក្ខុវិស័យ

ធានាការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងថាមពលប្រកបដោយភាពបៃតងដែលត្រូវចូលរួមចំណែកទទួលយក ការបន្សាំ ការការពារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដើម្បីអភិវឌ្ឍប្រកបដោយចីរភាពលើផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

នាពេលបច្ចុប្បន្ននេះ មានទំនាក់ទំនងដែលមិនអាចប្រកែកបានរវាងការប្រែប្រួលអាកាសធាតុពិភពលោក និងសកម្មភាពរបស់មនុស្សលើបរិស្ថាន។ ព្រះរាជាណាចក្រកម្ពុជាមិនមែនជាប្រទេសឧស្សាហកម្មនោះទេ ប៉ុន្តែជាប្រទេសមួយដែលត្រូវបានចាត់ទុកថាជាប្រទេសងាយទទួលរងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុខ្លាំងបំផុត។ ចក្ខុវិស័យនៃយុទ្ធសាស្រ្តធ្វើឲ្យមានចីរភាពនៃការទទួលយកការបន្សាំ ការការពារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៃវិស័យឧស្សាហកម្មកម្មន្តសាល និងថាមពល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវពិនិត្យទៅលើភាពចំបាច់នូវផលប្រយោជន៍ដោយចំណេញទាំងផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានដែលមិនអាចខ្វះបាន។ ចក្ខុវិស័យនេះគឺផ្អែកលើតំរូវការសំរាប់ការឆ្លើយតបប្រកបដោយនិរន្តភាពទាំងរយៈពេលខ្លី មធ្យម និងវែងចំពោះការប្រែប្រួលអាកាសធាតុ។

### ៨.២. បេសកកម្ម

តំរូវការសំរាប់ការឆ្លើយតបប្រកបដោយនិរន្តភាព ទាំងរយៈពេលខ្លី មធ្យម និងវែង ចំពោះការប្រែប្រួលអាកាសធាតុដែលជាចក្ខុវិស័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បេសកកម្មត្រូវបានកំណត់នូវរបៀបវារៈជាក់លាក់ចាំបាច់ដើម្បីធានាចំពោះការឆ្លើយតបប្រកបដោយភាពជោគជ័យ និងសំរេចបានតាមចក្ខុវិស័យ។ របៀបវារៈជាក់លាក់នេះ សំដៅទៅលើ៖

- ការកសាង និងការគាំទ្រខាងបទបញ្ញត្តិ និងគោលនយោបាយ
- ការកសាង និងការគាំទ្រលើផ្នែកបទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំ

- ការកសាង និងការអភិវឌ្ឍន៍ស្ថាប័នកិច្ច និងការពង្រឹងសមត្ថភាពធនធានមនុស្ស
- ការកសាងឲ្យមានយន្តការទំនាក់ទំនង ផ្សព្វផ្សាយ និងការផ្លាស់ប្តូរព័ត៌មាន
- ការទទួលយកបច្ចេកវិទ្យា ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង និងបទពិសោធន៍ស្តីពីឧស្សាហកម្មបៃតង និងថាមពលបៃតង
- ការជំរុញឲ្យមានការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍បច្ចេកវិទ្យាក្នុងស្រុកដែលមានលក្ខណៈបៃតងសំរាប់វិស័យឧស្សាហកម្ម និងថាមពល
- ការកសាងឲ្យមានចលនាមូលនិធិរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធ ទាំងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង រដ្ឋាភិបាល
- ការជំរុញលើកទឹកចិត្តដល់វិស័យឯកជនចូលរួមក្នុងការអនុវត្តន៍លើការប្រែប្រួលអាកាសធាតុ
- ការបញ្ជ្រាបយេនឌ័រក្នុងកិច្ចការចូលរួមអនុវត្តលើការប្រែប្រួលអាកាសធាតុ។

### ៨.៣. គោលដៅ និងគោលបំណង

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានគោលដៅ និងគោលបំណងរួម ដើម្បីចូលរួមសហការការអនុវត្តន៍ ការសម្របសម្រួលការចែករំលែករាល់ព័ត៌មាន ទិន្នន័យ ចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងវិស័យរបស់ខ្លួន ដើម្បីទទួលយក ការបន្សាំ ការការពារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុទៅតាមផែនការរយៈពេលខ្លី មធ្យម និងវែង។ គោលដៅ និងគោលបំណង នឹងបកស្រាយកាន់តែច្បាស់លាស់ និងប្រាកដប្រជាពីបេសកកម្មខាងលើតាមរយៈការកសាងយុទ្ធសាស្ត្រផែនការសកម្មភាពជាក់លាក់ កម្មវិធីការងារ ការកំណត់ពីសូចនករជាក់លាក់ កត្តាចូលរួម និងការវាយតម្លៃពីផលប៉ះពាល់ទៅនឹងលទ្ធផលរំពឹងទុកនៃការអនុវត្តន៍ផែនការនីមួយៗ ក៏នឹងវិភាគពីចំណុចខ្លាំង ចំណុចខ្សោយ ការគំរាមកំហែង និងកាលានុវត្តភាព ដោះស្រាយរាល់បញ្ហាជាក់ស្តែង ការប្រមើលទុកជាមុននៅក្នុងការងារអនុវត្តផែនការឲ្យសំរេចបានតាមការកំណត់។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងប្រើប្រាស់ឲ្យអស់ពីលទ្ធភាព និងសមត្ថភាពទាំងផ្នែកទន់ និងផ្នែករឹងនៃធនធានដែលមានស្រាប់ គួបផ្សំនឹងជំនួយពីប្រភពដៃគូអភិវឌ្ឍន៍ទាំងក្នុង និងក្រៅស្រុក ការកៀងគរធនធាន និងការចូលរួមពីគ្រប់ដៃគូពាក់ព័ន្ធ ជាពិសេសពីវិស័យឯកជន ដើម្បីកំណត់គោលដៅជាក់លាក់ដែលអាចសំរេចបានទៅតាមការគ្រោងទុក។

ក្រុមការងារបច្ចេកទេសទទួលបន្ទុកលើការកសាងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុលើវិស័យឧស្សាហកម្ម និងថាមពលបានកំណត់គោលដៅ និងគោលបំណងមួយចំនួនដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពស្ថាប័នកិច្ច និងការអភិវឌ្ឍន៍ធនធានមនុស្សទាំងស្ថាប័នរដ្ឋ និងវិស័យឯកជន
- ជំរុញ និងបង្កើតឲ្យមានការគាំទ្រផ្នែកសំភារៈ និងបរិក្ខាក្នុងការបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ
- បង្កើតឲ្យមានយន្តការផ្សព្វផ្សាយ ទំនាក់ទំនង និងការផ្លាស់ប្តូរព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុវិស័យទាំងពីរដល់ភាគីពាក់ព័ន្ធ និងដល់ក្រុមគោលដៅដែលងាយរងគ្រោះ
- កំណត់នូវចំណុចអាទិភាពនៃវិស័យឧស្សាហកម្ម និងថាមពលដែលទាក់ទងនឹងឥទ្ធិពលប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ
- ជំរុញ និងបង្កើតឲ្យមានមូលនិធិអភិវឌ្ឍន៍សំរាប់ធានាការអនុវត្តន៍ឲ្យមានចីរភាពនៃផែនការ

យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពល

- ទទួលបាននូវការផ្ទេរបច្ចេកវិទ្យាដែលមានលក្ខណៈប្រកបដោយឧស្សាហកម្ម និងថាមពលបៃតង
- បង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងទិន្នន័យច្បាស់លាស់ពីប្រភព និងកំរិតនៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ជំរុញ និងលើកទឹកចិត្តដល់អ្នកសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាដែលជួយដល់ការការពារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ជំរុញ និងលើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជន ក្រុមគោលដៅដែលងាយរងគ្រោះ
- ជំរុញ និងបង្កើតបន្ថែមឲ្យមានស្ថាប័នសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍បច្ចេកវិទ្យា នឹងកន្លែងដែលជួយធ្វើឲ្យឧស្សាហកម្ម និងថាមពលមានលក្ខណៈបៃតង
- ពិនិត្យ និងវាយតម្លៃចំណុចដែលត្រូវបំពេញបន្ថែមទៅលើបទបញ្ញត្តិ បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំដែលមានស្រាប់ ដើម្បីដាក់បញ្ចូលប្រធានបទការប្រែប្រួលអាកាសធាតុ
- សំណើឲ្យមានការកសាងច្បាប់ អនុក្រិត្យ ប្រកាស បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៃវិស័យទាំងពីរ ដើម្បីគាំទ្រលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ
- ការបញ្ជ្រាបយេនឌ័រ ដើម្បីឲ្យយល់ពីការប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យទាំងពីរ។

ដើម្បីសំរេចបាននូវគោលដៅ និងគោលបំណងខាងលើ ក្រុមការងារបានលើកយកប្រធានបទមួយចំនួនដែលមានស្រាប់ដូចជា៖

- ឧស្សាហកម្មបៃតង
- ថាមពលបៃតង
- ប្រសិទ្ធភាពថាមពល
- ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកំណត់ចំណុចបំពុលខ្លាំង និងការផ្ទេរបច្ចេកវិទ្យាអំណោយផលដល់បរិស្ថាន (ផលិតកម្ម និងបច្ចេកវិទ្យាស្អាត គណនេយ្យភាពនៃការគ្រប់គ្រង បរិស្ថាន ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ការទទួលខុសត្រូវសង្គម)
- ការច្នៃម៉ូតផលិតផលដែលមានចីរភាព
- ថាមពលពន្លឺព្រះអាទិត្យ
- ថាមពលជីវម៉ាស
- ថាមពលខ្យល់
- ថាមពលជីវឧស្ម័ន
- ថាមពលវារីអគ្គិសនី។ល។ ដើម្បីពង្រីកវិសាលភាពសកម្មភាពការងារពីទ្រង់ទ្រាយនៃការសិក្សា និងការអនុវត្តន៍គម្រោងគំរូឲ្យទៅជាទ្រង់ទ្រាយដែលមានវិសាលភាពគ្រប់ដណ្តប់ទូទាំងប្រទេស។

## ៨.៤.ក្របខណ្ឌយុទ្ធសាស្ត្រ

❖ **ការវិភាគជាយុទ្ធសាស្ត្រ**

**គ. ចំណុចខ្សោយ**

- បរិមាណប្រើប្រាស់អគ្គិសនីពុំទាន់គ្រប់គ្រាន់ និងមានតម្លៃខ្ពស់៖ កត្តាប្រឈមសំខាន់ៗចំពោះការបង្កើតសហគ្រាសផលិតគឺ៖ តម្លៃអគ្គិសនី និងភាពខ្វះខាត ការផ្គត់ផ្គង់អគ្គិសនីតាមរយៈការប្រៀបធៀបតម្លៃអគ្គិសនីដែលនាំចូលពីប្រទេសជិតខាងឃើញថាមានតម្លៃខ្ពស់ជាងពាក់កណ្តាល។

- កង្វះខាតថវិកា ឬ ហិរញ្ញប្បទាន៖ ការទទួលបានហិរញ្ញវត្ថុតាមរយៈឥណទាន និងជំនួយឥតសំណងជាកត្តាចំបងដែលវិស័យឧស្សាហកម្ម និងថាមពលត្រូវការចំបាច់ដើម្បីពង្រីក និងពង្រឹងផលិតភាព និងភាពប្រកួតប្រជែងទាំងក្នុងស្រុក និងអន្តរជាតិផងដែរ។

- ប្រសិទ្ធភាពថាមពលនៅមានភាពទន់ខ្សោយក្នុងវិស័យឧស្សាហកម្មដ៏ទៀតដូចជា៖ វាយនភ័ណ្ឌឡឥដ្ឋ រោងម៉ាស៊ីនកិនស្រូវ និងរោងចក្រផលិតក្រដាសជាដើម ។ល។ ក៏នៅកំរិតខ្ពស់ក្នុងការប្រើប្រាស់ថាមពលមិនមានប្រសិទ្ធភាពដែលក្នុងការផលិតផលិតមួយឯកតាឃើញថាមានប្រើប្រាស់ថាមពលខ្ពស់ផងដែរ។

- ការប្រើប្រាស់ម៉ាស៊ូត និងឥន្ធនៈផ្សេងៗ៖ យើងពិនិត្យឃើញថាឧស្សាហកម្មបានប្រើប្រាស់ប្រេងម៉ាស៊ូត និងឥនន្ធៈផ្សេងៗខ្ពស់ ដូចជាឧស្សាហកម្មវាយនភ័ណ្ឌ និងកែច្នៃម្ហូបអាហារចំណែកឡឥដ្ឋក៏មានការប្រើប្រាស់ថាមពលដោយប្រើប្រាស់អុស ដែលជាបញ្ហានាំឲ្យមានការកាប់បំផ្លាញព្រៃឈើ និងការបំពុលដល់បរិស្ថាន។ បញ្ហាទាំងអស់នេះអាចមានជំរើសច្រើនក្នុងការកាត់បន្ថយការបំភាយជាតិពុលបានតាមរយៈការអនុវត្តន៍ការសន្សំសំចៃថាមពល និងផ្លាស់ប្តូរបច្ចេកវិទ្យាដែលមានលក្ខណៈប្រកបដោយបរិស្ថាន។

- ការប្រមូលប្រព័ន្ធទិន្នន័យបំភាយឧស្ម័នផ្ទះកញ្ចក់ពុំទាន់គ្រប់គ្រាន់៖ ទិន្នន័យកំរិតបំភាយ ឧស្ម័នកាបូនិកតាមប្រភពកន្លែងទីតាំងផលិតនៅមានកំរិត ថ្វីត្បិតតែមានការវិភាគទស្សន៍ទាយពីកំរិតបំភាយឧស្ម័នកាបូនិក នៅក្នុងវិស័យឧស្សាហកម្មក្តី ជាលក្ខណៈទ្រង់ទ្រាយតូច និងតាមការអនុវត្តន៍គម្រោងគំរូដែលជាទិន្នន័យមូលដ្ឋាន ហើយបានប៉ាន់ស្មានថាកំរិតបំភាយនៃឧស្ម័នកាបូនិកនឹងកើនឡើងប្រហែល ១០ដង នៅក្នុងឆ្នាំ ២០៥០។

- កង្វះខាតការផ្គត់ផ្គង់ឧបករណ៍ដែលមានលក្ខណៈសន្សំសំចៃថាមពល យើងពិនិត្យឃើញថាឧបសគ្គសំរាប់ការទទួលយកចំណេះដឹងផ្នែកប្រសិទ្ធភាពថាមពលដោយ៖ ការផ្គត់ផ្គង់ឧបករណ៍សំភារៈដែលមានលក្ខណៈសន្សំសំចៃថាមពលនៅមានកំរិត ដោយការយល់ដឹងរបស់អ្នកប្រើប្រាស់នៅមានកំរិត សមត្ថភាពបច្ចេកទេសរបស់រដ្ឋនៅភាពប្រឈមដោយកង្វះខាតថវិកា ធនធានមនុស្ស និងជំនាញជាក់លាក់។

- កង្វះខាតការយល់ដឹងរបស់អ្នកគ្រប់គ្រងពីការសន្សំសំចៃថាមពល៖ កង្វះខាតការយល់ដឹងលើការគ្រប់គ្រងថាមពល និងការសន្សំថាមពលរបស់អ្នកមានសិទ្ធធ្វើសេចក្តីសំរេច ព្រមទាំងក្នុងរោងចក្រសហគ្រាស និងសិប្បកម្ម ដោយធ្វើការសន្និដ្ឋានអត្តនោម័តលើទិដ្ឋភាពនៃតម្លៃថាមពលខ្ពស់ ដោយពុំមានព័ត៌មានគ្រប់គ្រាន់ និងការយល់ដឹងពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៅមានកំណត់។

- សមត្ថភាពបច្ចេកទេសរបស់បុគ្គលិកសហគ្រាសឯកជនក៏នៅមានកំរិត៖ ជាការចាំបាច់ណាស់សំរាប់វិស័យឯកជន និងម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្មត្រូវទទួលការយល់ដឹងច្បាស់លាស់អំពីការវិភាគស្ថានភាពប្រើប្រាស់ថាមពលយល់ដឹងពីប្រសិទ្ធភាពថាមពល និងឥទ្ធិពលនៃលក្ខខណ្ឌ

ប្រតិបត្តិ។ សហគ្រាសនាំចេញមួយចំនួនផ្នែកកាត់ដេរ និងវាយនភ័ណ្ឌក៏មានការកត់ត្រា និងធ្វើរបាយការណ៍ពីការប្រើប្រាស់ថាមពលអគ្គិសនីតិចតួចដែរដែលជាកត្តាមូលដ្ឋានសំរាប់ការធ្វើផែនការការវាយតម្លៃ និងការអនុវត្តន៍គម្រោងពុំមានលក្ខណៈសមស្របតាមអភិក្រមជាប្រព័ន្ធ ហើយសហគ្រាសធុនតូចជាច្រើនទៀតដូចជារោងម៉ាស៊ីនកិនស្រូវ ឡូតដូ ភេសជ្ជៈ ចំណីអាហារ និងផលិតក្រដាសក៏ពុំទាន់យល់ដឹងច្បាស់លាស់ពីផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានពីវិធានការសន្សំថាមពលការកសាង និងការអនុវត្តន៍ការគ្រប់គ្រងថាមពល។

– ចំពោះក្នុងចំណោមអ្នកលក់ឧបករណ៍ គ្រឿងបរិក្ខា និងអ្នកផ្តល់សេវាក៏ពុំយល់គ្រប់គ្រាន់ពីប្រសិទ្ធភាពថាមពល និងជំនាញនេះផងដែរ។ សូម្បីតែអ្នកនាំចូលបច្ចេកវិទ្យាផលិត និង អ្នកផ្គត់ផ្គង់ពីប្រទេសផ្សេងទៀតចូលក្នុងប្រទេស ក៏ភាគច្រើនពុំទាន់យល់ច្បាស់ពីប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ថាមពលឲ្យប្រសើរឡើងដែរ។

– កង្វះខាតអ្នកបច្ចេកទេស និងមន្ត្រីជំនាញមានសមត្ថភាពផ្នែកសនវកម្មថាមពលក៏ជាឧបសគ្គរបស់រាជរដ្ឋាភិបាលសំរាប់ការធ្វើឲ្យប្រសើរឡើងលើការអនុវត្តន៍គម្រោងប្រសិទ្ធភាពថាមពលបានឆាប់រហ័សផងដែរ។

– កង្វះខាតថវិកា និងឥណទានរបស់ស្ថាប័នរដ្ឋ និងវិស័យឯកជនក៏ជាបញ្ហាផ្សេងទៀត វិស័យឯកជនត្រូវការអភិវឌ្ឍន៍ និងបំពាក់បន្ថែមផ្នែកបច្ចេកវិទ្យាផលិតកម្មរបស់ខ្លួនចាំបាច់ត្រូវធានានិរន្តភាពផ្នែកថវិកា។

### ខ. ចំណុចខ្លាំង

- **ការធ្វើសមាហរណកម្មផ្នែកពាណិជ្ជកម្ម និងនយោបាយក្នុងតំបន់ និងពិភពលោក**

ប្រទេសកម្ពុជា នាបច្ចុប្បន្នមានស្ថេរភាពនយោបាយល្អប្រសើរដែលផ្តល់បរិយាកាសអនុគ្រោះសំរាប់ការហូរចូលការវិនិយោគពីក្នុងនិងក្រៅប្រទេសដោយពិនិត្យជាក់ស្តែងឃើញថាកំណើនវិនិយោគទុនបរទេសមានការកើនឡើង ព្រមទាំងថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជាទទួលបានតំណែងជាប្រធានសហគមន៍អាស៊ាន ដើម្បីដឹកនាំកិច្ចប្រជុំថ្នាក់កំពូលនៃប្រទេសជាសមាជិកអាស៊ានជាមួយដៃគូអភិវឌ្ឍន៍ពីប្រទេសផ្សេងៗនៅក្នុងពិភពលោកដែលសបញ្ជាក់ពីសក្តានុពល និងភាពប្រាកដប្រាជាក្នុងការសំរបសំរួលការងារអាស៊ានទាំងមូល និងពិភពលោក។ ក្នុងព្រឹត្តិការណ៍នេះ បានទាក់ទាញអ្នកវិនិយោគពីប្រទេសធំៗ មិនត្រឹមតែក្របខណ្ឌអាស៊ាននោះទេ តែព្រមទាំងប្រទេសមហាអំណាចក្នុងពិភពលោកផងដែរ។

កម្ពុជា ក៏បានចូលជាសមាជិកក្នុងការអនុវត្តន៍យុទ្ធសាស្ត្រការប្រែប្រួលសាកលដែរ នឹងក៏បានចូលជាសមាជិកអនុវត្តអនុសញ្ញាផ្សេងៗទៀត ដូចជា៖ អនុសញ្ញាស្តុកខូម (Stockholm Convention) គឺជាអនុសញ្ញាដែលស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលបានប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្ម និងវិស័យថាមពលហើយកម្ពុជាក៏បានចូលរួមចុះហត្ថលេខាជាមួយអនុសញ្ញា២ទៀតដែរ គឺអនុសញ្ញាបាសែល អនុសញ្ញារ៉ូតឺដាំផងដែរ។

- **មានផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ជាត្រីវិស័យ**
- **មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩ ដល់២០១៣ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាបច្ចុប្បន្នភាពឆ្នាំ២០១០ ជាទិសដៅតំរង់ផ្លូវសំរាប់ការអនុវត្តន៍**

- **វិស័យឧស្សាហកម្ម និងថាមពលជាការងារស្នូលរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលកំណត់ដោយរាជរដ្ឋាភិបាល**

រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់សិទ្ធិ និងតួនាទីសំខាន់ដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លើការកសាង និងអភិវឌ្ឍវិស័យឧស្សាហកម្ម សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងថាមពល។ វិស័យទាំងនេះជាស្នូលយ៉ាងសំខាន់ ដើម្បីជំរុញ និងអភិវឌ្ឍកំណើនសេដ្ឋកិច្ចជាតិ។

- **ច្បាប់ គោលនយោបាយ និងធនធានមនុស្សដែលមានស្រាប់**

បច្ចុប្បន្ននេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានច្បាប់ និងគោលនយោបាយពាក់ព័ន្ធមួយចំនួនដែលមានស្រាប់ និងកំពុងដំណើរការរៀបចំបន្តសំរាប់ការគ្រប់គ្រង និងអនុវត្តផែនការលើវិស័យឧស្សាហកម្ម និងថាមពល ដើម្បីធានាឲ្យមានភាពប្រកួតប្រជែងក្នុងស្រុក និងអន្តរជាតិ។

មន្ត្រីជំនាញរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានទទួលការបណ្តុះបណ្តាល និងសិក្ខាសាលាទាំងថ្នាក់ជាតិ និងអន្តរជាតិ ក្នុងការពង្រឹង សមត្ថភាពបន្ថែមទៅតាមជំនាញនីមួយៗ ដើម្បីឲ្យឆ្លើយតបតាមតំរូវការធនធានមនុស្សតាមជំនាញ នាពេលបច្ចុប្បន្នក៏ដូចជាសំរាប់ពេលអនាគតហើយក្រសួងក៏បានអនុវត្តគម្រោងទ្វេរភាគី និងពហុភាគីជាមួយដៃគូរអភិវឌ្ឍន៍ជាច្រើនទៀតដែលជាទុនមូលដ្ឋាន ដើម្បីពង្រឹងបទពិសោធន៍ថ្មីៗបន្ថែមទៀត។

- **កាលានុវត្តន៍ភាពនៃប្រភពធនធានសំរាប់ការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងថាមពល**

ដើម្បីអនុវត្តវិស័យថាមពលដែលផលិតចេញពីវារីអគ្គិសនី ទីតាំងភូមិសាស្ត្រនៃប្រទេសកម្ពុជាមានលក្ខណៈអំណោយផលដែលមានប្រភពទឹកសំរាប់កសាងស្ថានីយ៍វារីអគ្គិសនីសំរាប់បំរើដល់តំរូវការរបស់ប្រជាពលរដ្ឋ តំរូវការថាមពលក្នុងវិស័យឧស្សាហកម្ម និងបំរើសេវាកម្មផ្សេងៗ ហើយកម្ពុជាក៏ជាប្រទេសដែលសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្មជាអាទិភាព រួមទាំងទេសចរណ៍។

ដោយពិនិត្យទៅលើកាលានុវត្តភាពខាងលើគោលនយោបាយឧស្សាហកម្មកម្មត្រូវចាប់ផ្តើមលើឧស្សាហកម្មដែលប្រើប្រាស់កំលាំងពលកម្មច្រើនជាងកំលាំងម៉ាស៊ីន គ្រឿងចក្រ និងបច្ចេកវិទ្យាដែលបង្កភាពងាយស្រួលក្នុងការធ្វើកំណែទំរង់ខ្សែសង្វាក់ផលិតកម្មរបស់រោងចក្រ សហគ្រាស និងសិប្បកម្មនានាក្នុងការប្រើប្រាស់ប្រភពធនធានដែលមិនប៉ះពាល់ដល់បរិស្ថាន ហើយគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មក៏ពុំទាន់មានការវិនិយោគណាដែលបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និង សង្គមនៅឡើយទេ។

### គ. បញ្ហាប្រឈមពាក់ព័ន្ធនឹង អន្តរវិស័យ

ចំពោះរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធក៏ត្រូវមានការគាំទ្រគ្រាប់គ្រាន់ និងមាននិរន្តភាពផ្នែកថវិកា ដើម្បីពង្រឹងសមត្ថភាពមន្ត្រី ផ្សព្វផ្សាយ ធ្វើសវនកម្ម និងមានប្រព័ន្ធទិន្នន័យច្បាស់លាស់ពីការគ្រប់គ្រងថាមពលនេះ ការកសាង និងពង្រឹងច្បាប់ បទដ្ឋានបច្ចេកទេស ដើម្បីអនុវត្តផែនការ និងគោលនយោបាយមានប្រសិទ្ធភាព និងនិរន្តភាព នាពេលអនាគត។

- ថវិកាកសាង និងអនុវត្តផែនការ
- ការកសាងបទបញ្ញត្តិ
- ការបញ្ច្រាបយេនឌ័រ
- កិច្ចសហការ និងកិច្ចសម្របសម្រួល

- ការតាមដាន និងការវាយតម្លៃផែនការ
- ការផ្សព្វផ្សាយ និងផ្លាស់ប្តូរព័ត៌មាន
- ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍បច្ចេកវិទ្យាបៃតង។

### ៨.៥. កម្មវិធីដែលត្រូវអនុវត្តបន្ត

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលធ្វើយ៉ាងណាពុះពារ ដោះស្រាយរាល់បញ្ហាប្រឈមក្នុងការអនុវត្តន៍ការងារកន្លងមកដូចបានអធិប្បាយខាងលើ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់ខ្លួន។

ការអនុវត្តន៍កម្មវិធីបន្តធ្វើឡើងទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិបច្ចុប្បន្នភាព និងបត់បែនទៅតាមស្ថានភាពប្រឈមដែលកើតមានឡើងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។

ចំណុចខាងក្រោមនេះ នឹងបរិយាយពីគោលបំណង និងសកម្មភាពសំខាន់ៗមួយចំនួន ដើម្បីការបន្សាំ ការការពារ និងការដំណោះស្រាយបញ្ហាការងារដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលដែលជាការវាយតម្លៃ និងការសន្និដ្ឋានរួមរបស់ក្រុមការងារកសាងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពល។

## ៩. សុពលភាពនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអនុវត្តភារកិច្ច និងតួនាទីអនុលោមទៅតាមរយៈការដឹកនាំការគ្រប់គ្រង និងការតំរង់ទិសពីថ្នាក់ដឹកនាំ និងពីរាជរដ្ឋាភិបាលកម្ពុជាដែលមានអាណត្តិរបស់ខ្លួន ៥ឆ្នាំម្តង ក្រសួងក៏ត្រូវធ្វើផែនការអនុវត្ត ដើម្បីអភិវឌ្ឍវិស័យរបស់ខ្លួនទៅតាមផែនការយុទ្ធសាស្ត្រ របៀបវារៈ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលបានកំណត់។ ដូចនេះ សុពលភាពនៃការកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនេះ មានរយៈពេល៥ឆ្នាំម្តង តែរក្សាសិទ្ធិ និងតួនាទីរបស់ខ្លួនក្នុងការធ្វើការពិនិត្យឡើងវិញ ការវាយតម្លៃ និងការកែតំរូវផែនការនេះ ក្រោយបញ្ចប់រយៈពេល ៥ឆ្នាំម្តង ដែលត្រូវឆ្លុះបញ្ចាំង និងមានភាពបត់បែនតាមការតំរង់ទិស និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានៃអាណត្តិបន្ទាប់។

## ១០. សន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពលគឺជាឯកសារបច្ចេកទេសមូលដ្ឋានគោលមួយដែលមានបំណងជួយដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលក្នុងការបញ្ជ្រាបប្រធានបទការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍វិស័យឧស្សហកម្ម និងថាមពលដែលកំណត់ជារយៈពេលខ្លី មធ្យម និងវែង ព្រមទាំងជួយដល់ក្រុមការងារសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីដាក់បញ្ចូលជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា។

ផែនការយុទ្ធសាស្ត្រនេះមានបំណងទទួលយកការបន្សាំ ការកាត់បន្ថយ ការការពារការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលទៅតាមបរិបទជាក់ស្តែងរបស់កម្ពុជា និងទំនោរបត់បែននៃបរិបទពិភពលោក។ ឥរិយាបថនៃការទទួលយក និងការបន្សាំនៃការប្រែប្រួលអាកាសធាតុដែលជាបញ្ហាមិនអាចប្រកែក និងជំទាស់បានទៅនឹងអ្វីដែលពិភពលោកកន្លងមកបាននឹងកំពុងបន្តប្រឈម

ដែលយើងគ្រប់រូប គ្រប់ជាតិសាសន៍នៃពិភពលោកទាំងមូលត្រូវតែទទួលស្គាល់នូវបញ្ហានេះ ហើយចាំបាច់ត្រូវសំរបខ្លួន ឥរិយាបថ និងការទទួលយក ដើម្បីអនុវត្ត និងការប្រព្រឹត្តទៅរបស់មនុស្សជាតិទាំងមូលប្រកបដោយភាពសុខសាន្ត និងវឌ្ឍនភាព។ ការទទួលយក និងការបន្សាំនៃការប្រែប្រួលអាកាសធាតុ គឺជាការផ្លាស់ប្តូរទម្លាប់ ឥរិយាបថ និងការអនុវត្តន៍របស់យើងគ្រប់គ្នាឲ្យស្របទៅតាមការប្រែប្រួលនៃបរិបទសេដ្ឋកិច្ច សង្គម និងបរិស្ថានរបស់ពិភពលោកទាំងមូល។ វិធានការនៃការទទួលយក និងការបន្សាំនេះ ធ្វើឡើងទៅតាមរយៈការផ្សព្វផ្សាយចំណេះដឹង ព័ត៌មាន បទពិសោធន៍ កំរិតនៃឥទ្ធិពលផលប៉ះពាល់ដល់សុខភាពមនុស្ស សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ចក្ខុវិស័យនៃការកាត់បន្ថយ និងការការពារការប្រែប្រួលអាកាសធាតុក្នុងវិស័យឧស្សាហកម្ម និងថាមពលត្រូវបានបកស្រាយជាបេសកកម្ម គោលដៅ និងគោលបំណង ព្រមទាំងផែនការសកម្មភាពជាក់លាក់សំដៅទៅលើវិធានការទាំងឡាយណាដែលគ្របដណ្តប់ពី ថ្នាក់សាកលលោក ថ្នាក់តំបន់ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគ្រប់ស្រទាប់ប្រជាពលរដ្ឋទូទៅដែលត្រូវអនុវត្តផ្ទាល់ និងងាយរងគ្រោះត្រូវមានវិធានការទាំងផ្នែកច្បាប់ បទដ្ឋានបច្ចេកទេស ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍បន្ថែមការទទួលយកបច្ចេកវិទ្យាថ្មី និងការច្នៃប្រឌិតបច្ចេកវិទ្យា ប្រព័ន្ធចែករំលែកព័ត៌មាន ទិន្នន័យ និងចលនាកៀងគរធនធានសំរាប់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងថ្នាក់ធ្វើការសំរេចចិត្តផ្នែកគោលនយោបាយ ធ្វើផែនការអនុវត្ត និងការផ្សព្វផ្សាយ ព្រមទាំងអ្នកអនុវត្ត និងភាគីងាយរងគ្រោះពីគ្រប់ភាគីពាក់ព័ន្ធត្រូវមានវិធានការការពារទុកជាមុន វិធានការកាត់បន្ថយហានិភ័យមុនពេលមានបញ្ហាកើតឡើង និងការឆ្លើយតបទាន់ពេលវេលានៅពេលមានបញ្ហាកើតឡើង។

ដើម្បីសំរេចបានជោគជ័យនៃការអនុវត្តន៍ផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពល ទាំងរយៈពេលខ្លី មធ្យម និងវែងចាំបាច់ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដូចជា៖ រដ្ឋាភិបាល សាកលវិទ្យាល័យ វិស័យឯកជន អង្គការជាដៃគូអភិវឌ្ឍន៍នានា និងផ្នែកយេនឌ័រ ព្រមទាំងមានការគាំទ្រទាំងជំនួយបច្ចេកទេស និងថវិកាផងដែរ។

ថ្វីត្បិតតែប្រទេសកម្ពុជា ជាប្រទេសមួយដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុសាកលក៏ដោយ ក៏យើងទាំងអស់គ្នាមានឆន្ទៈ ការប្តេជ្ញាចិត្តចូលរួមចែករំលែក និងដោះស្រាយរាល់បញ្ហាការប្រែប្រួលអាកាសធាតុនេះ ក្នុងន័យធ្វើឲ្យពិភពលោកទាំងមូល និងប្រជាជនរបស់យើងរស់នៅក្នុងសេដ្ឋកិច្ច សង្គម និងបរិស្ថានមួយដែលប្រកបដោយភាពសុខសាន្ត វឌ្ឍនភាព និងនិរន្តភាព។

ក្នុងន័យខាងលើនេះ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាសេនាធិការនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានតួនាទី និងកាតព្វកិច្ចរបស់ខ្លួន ដើម្បីអនុវត្តផែនការយុទ្ធសាស្រ្តប្រែប្រួលអាកាសធាតុទាក់ទងនឹងវិស័យឧស្សាហកម្ម និងថាមពលឲ្យបានជោគជ័យ និង ប្រសិទ្ធភាពទៅតាមអាណត្តិរបស់ខ្លួន។

## ១២. ឯកសារយោង


១. យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី០២

២. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣

៣. គោលដៅអភិវឌ្ឍន៍សហវត្សរបស់កម្ពុជា

៤. របាយការណ៍បូកការងារឧស្សាហកម្ម រ៉ែ និងថាមពលឆ្នាំ២០១១ និងទិសដៅការងារសំរាប់ឆ្នាំ២០១២
៥. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យឧស្សហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម
៦. សេចក្តីព្រាងលើកកំពស់ចំណេះដឹង និងការអប់រំស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ២០១២-២០១៤
៧. Cambodia´s Second National Communication, 2010: Greenhouse Gas Mitigation Analyses for the Energy and Transport, May 28th, 2010, Climate Change Department, Ministry of Environment
៨. Naron, 2009. Cambodian economy: Charting the course of a brighter future. A survey of proges, problems and prospects
៩. MEF, 2007 Macro-Economic Framework 2005, Ministry of Economy and Finance (MEF), Cambodia
១០. National Institute of Statistics (NIS), 2011-2012. SMEs research.